ក

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ១~ព្រះរាជក្រម


០៩-០១-២០១៤ -ព្រះរាជក្រម នស/រកម/០១១៤/០០២ ស្ដីពី ការប្រកាសឱ្យប្រើ ច្បាប់ ស្ដីពី ការអនុម័តយល់ព្រមលើពិធីសារទី៣ នៃការធ្វើវិសោធនកម្មកិច្ចព្រមព្រៀងក្របខ័ណ្ឌស្ដីពីសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍និងសាធារណរដ្ឋប្រជាមានិតចិន និងពិធីសារបញ្ចូលវិធានការអនទាម័យ និងភូតគាមអនាម័យ និងរបាំងបច្ចេកទេសពាណិជ្ជកម្ម ទៅក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌស្ដីពីសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋប្រជាមានិតចិន ៦០៦


### ២~ព្រះរាជក្រឹត្យ


២៦-១២-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១២១៣/១៤១៣ ស្ដីពី ការតែងតាំងមន្ត្រីរាជការចំនួន ០៣ រូប ជាទីប្រឹក្សាក្រសួងផែនការ មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន ៦៥៥

២៦-១២-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១២១៣/១៤១៤ ស្ដីពី ការតែងតាំង ទីប្រឹក្សាឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ចំនួន ០២ រូប បន្ថែមលើមុខងារបច្ចុប្បន្ន ដោយមិនយកប្រាក់បៀវត្ស ៦៥៦

២៦-១២-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១២១៣/១៤១៥ ស្ដីពី ការតែងតាំងឯកឧត្តម **ថែម ទិត្យ៉ា** ជា អនុរដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ៦៥៧

២៦-១២-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១២១៣/១៤១៦ ស្ដីពី ការតែងតាំងឯកឧត្តម **ស៊ា គុសល** ជាទីប្រឹក្សា និងនាយកខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ឋានៈស្មើ រដ្ឋលេខាធិការ ៦៥៨

២៦-១២-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១២១៣/១៤១៧ ស្ដីពី ការតែងតាំងមន្ត្រីរាជការចំនួន ០៩ រូប ជាទីប្រឹក្សាក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ៦៥៩

២៦-១២-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១២១៣/១៤១៨ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះកងកម្លាំងប្រដាប់អាវុធ ចំនួន ៤១៨ រូប ៦៦០

២៦-១២-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១២១៣/១៤១៩ ស្ដីពី ការតែងតាំងទីប្រឹក្សាឯកឧត្តម **សាយ ឈុំ** អនុប្រធានទី ១ នៃព្រឹទ្ធសភា នីតិកាលទី ៣ ចំនួន ០២ រូប ៦៧៣

២៦-១២-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១២១៣/១៤២០ ស្តីពី ការតែងតាំងឯកឧត្តម **សុខ លីហួត** ជាឧកញ៉ា ៦៧៤

២៦-១២-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១២១៣/១៤២១ ស្តីពី ការផ្ទេរមុខតំណែង និងតែងតាំងមន្ត្រី ចំនួន ០២ រូប នៅឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ៦៧៥

២៧-១២-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១២១៣/១៤២៣ ស្តីពី ការតែងតាំងទីប្រឹក្សា និងជំនួយការសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី ៥ ចំនួន ០៩ រូប ៦៧៦

## II. រាជរដ្ឋាភិបាល

### អនុក្រឹត្យ

០២-០១-២០១៤-អនុក្រឹត្យលេខ ០១ អនក្រ.បក ស្តីពី ការបន្ថែមបៀវត្សមូលដ្ឋានជូនមន្ត្រីរាជការស៊ីវិល ការបង្កើនប្រាក់អាហារប្រចាំថ្ងៃ ជូនយោធិន នគរបាលជាតិ និង មន្ត្រីពន្ធនាគារ និង ការផ្តល់ប្រាក់កម្រៃបន្ថែមជូនគ្រូបង្រៀនជាប់កិច្ចសន្យា ៦៧៨

០៦-០១-២០១៤-អនុក្រឹត្យលេខ ០២ អនក្រ.បក ស្តីពី ការកាត់ដីទំហំ ៤៣,៣១ ហិកតា នៅស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ ចេញពីដីតម្រូវព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៦៨ គ្រួសារ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ ៦៨១

០៦-០១-២០១៤-អនុក្រឹត្យលេខ ០៣ អនក្រ.បក ស្តីពី ការកាត់ដីទំហំ ៣.៦៤១ ហិកតា នៅស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ក្នុងនោះកាត់ចេញពីដីតម្រូវព្រៃឈើឆ្នាំ និងកាត់ចេញពីព្រៃសម្បទានរបស់ក្រុមហ៊ុន ធីម៉ាសវីសូស លីមីធីត និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋសម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៩៣២ គ្រួសារ ៦៨៥

០៨-០១-២០១៤-អនុក្រឹត្យលេខ ១៩ អនក្រ.តត ស្តីពី ការតាំងស៊ប់ក្នុងក្របខណ្ឌមន្ត្រីរាជការ ៦៨៩

០៩-០១-២០១៤-អនុក្រឹត្យលេខ ២០ អនក្រ.តត ស្តីពី ការផ្ទេរបញ្ចូលទៅក្នុងឋានន្តរស័ក្តិ នាយក្រមការ នៃក្របខ័ណ្ឌមន្ត្រីក្រមការ ៦៩៩

០៩-០១-២០១៤-អនុក្រឹត្យលេខ ២១ អនក្រ.តត ស្តីពី ការដំឡើងឋានន្តរស័ក្តិ តែងតាំង និងសម្រួលភារកិច្ចមន្ត្រីរាជការ ៧០១

០៩-០១-២០១៤-អនុក្រឹត្យលេខ ២២ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៧០៣

០៩-០១-២០១៤-អនុក្រឹត្យលេខ ២៣ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៧០៥

០៩-០១-២០១៤-អនុក្រឹត្យលេខ ២៤ អនក្រ.តត ស្តីពី ការដំឡើងឋានន្តរស័ក្តិ នាយនគរបាលជាន់ខ្ពស់ ៧០៦

# គ

## III-ការិយាល័យក្រសួង

## ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

១៩-១២-២០១៣ -ប្រកាសលេខ ១៤១០ សហវ.ប្រក ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋាន និងអង្គភាពក្រោមឱវាទរបស់អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ៧០៧

# ព្រះរាជក្រម

នស/រកម/០១១៤/០០៧

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ ស្តីពីការអនុម័តយល់ព្រមលើពិធីសារទី៣ នៃការធ្វើវិសោធនកម្មកិច្ចព្រមព្រៀងក្របខ័ណ្ឌ ស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋប្រជាមានិតចិន និងពិធីសារបញ្ចូលវិធានការអនាម័យ និងភូតគាមអនាម័យ និងរបាំងបច្ចេកទេសពាណិជ្ជកម្ម ទៅក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌ ស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋប្រជាមានិតចិន ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៣ នាសម័យប្រជុំរដ្ឋសភាលើកទី១ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគតិច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៣ នាសម័យប្រជុំលើកទី៤ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅៈ

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

# ច្បាប់
## ស្តីពី
## ការអនុម័តយល់ព្រមលើពិធីសារទី៣ នៃការធ្វើវិសោធនកម្មកិច្ចព្រមព្រៀង ក្របខ័ណ្ឌស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងសមាគម ប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋប្រជាមានិតចិន និង ពិធីសារបញ្ចូលវិធានការអនាម័យ និងភូតគាមអនាម័យ និង របាំងបច្ចេកទេសពាណិជ្ជកម្ម ទៅក្នុងកិច្ចព្រមព្រៀង ពាណិជ្ជកម្មទំនិញនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពី សហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាង សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និង សាធារណរដ្ឋប្រជាមានិតចិន

**មាត្រា ១.-**

អនុម័តយល់ព្រមលើពិធីសារទី៣ នៃការធ្វើវិសោធនកម្មកិច្ចព្រមព្រៀងក្របខ័ណ្ឌ ស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយ រវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋប្រជាមានិតចិន និងពិធីសារបញ្ចូលវិធានការអនាម័យ និងភូតគាមអនាម័យ និងរបាំងបច្ចេកទេសពាណិជ្ជកម្មទៅក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌ ស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋប្រជាមានិតចិន ដែលបានចុះហត្ថលេខានាថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១២ នៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តពិធីសារទី៣ និងពិធីសារនេះ។

**មាត្រា ៣.-**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៤

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

នស/រកម.០១១៤.០២៣ **នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**ហត្ថលេខា**

**អូន ព័ន្ធមុនីរ័ត្ន**

លេខ ៣៨ ស.ណ

**សំណៅដែលមានសេចក្តីថ្លែងថាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែមករា ឆ្នាំ២០១៤

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ១០៧ សរ/បក**

## សិទ្ធិប្រទាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## រាជរដ្ឋាភិបាលកម្ពុជា

ប្រគល់សិទ្ធិពេញសមត្ថភាពជូនឯកឧត្តម **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងជារដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន ដើម្បីចុះហត្ថលេខាក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា លើពិធីសារទី៣ ដើម្បីធ្វើវិសោធនកម្មកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពី សហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋប្រជាមានិតចិន ពិធីសារដើម្បីបញ្ចូលវិធានការអនាម័យនិងភូតគាមអនាម័យ និងរបាំងបច្ចេកទេសពាណិជ្ជកម្ម ទៅក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពី សហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋប្រជាមានិតចិន។

ក្នុងករណីឯកឧត្តម **ចម ប្រសិទ្ធ** មានធុរៈជាយថាហេតុ ឯកឧត្តមអាចផ្ទេរសិទ្ធិនេះបាន។

អាស្រ័យហេតុនេះ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដោយមានសិទ្ធិពេញលេញតាមអំណាចដែលច្បាប់បានប្រគល់ជូនបានចុះហត្ថលេខាលើសិទ្ធិប្រទាននេះ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ [illegible] ឆ្នាំ ២០១២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*បកប្រែក្រៅផ្លូវការ*

# ពិធីសារទី៣ ដើម្បីធ្វើវិសោធនកម្ម កិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពី សហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាង សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋប្រជាមានិតចិន

៚✱៛

**រដ្ឋាភិបាល** នៃប្រទេសប្រ៊ុយណេដារូសាឡាំ ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋឥណ្ឌូនេស៊ី សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ ម៉ាឡេស៊ី សហភាពមីយ៉ាន់ម៉ា សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសិង្ហបុរី ព្រះរាជាណាចក្រថៃ និងសាធារណរដ្ឋសង្គមនិយមវៀតណាម បណ្តារដ្ឋសមាជិកនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (ទាំងអស់ហៅកាត់រួមគ្នាថា "អាស៊ាន" ឬ "បណ្តារដ្ឋសមាជិកអាស៊ាន" ឬរដ្ឋនីមួយៗហៅថាប្រទេសសមាជិកអាស៊ាន និងសាធារណរដ្ឋប្រជាមានិតចិន ("ចិន") ដែលខាងក្រោមនេះហៅថា "បណ្តាភាគី" ឬរៀងៗខ្លួនសំដៅលើរដ្ឋសមាជិកអាស៊ាន ឬចិនហៅថា "ភាគី"

**ដោយរំលឹកឡើងវិញ** កិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពី សហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងបណ្តាប្រទេសសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋប្រជាមានិតចិន (ដែលខាងក្រោមនេះហៅថា "កិច្ចព្រមព្រៀងក្របខ័ណ្ឌ") ដែលបានចុះហត្ថលេខានាថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០០២ និងកថាខណ្ឌ១ នៃមាត្រា១២ (ការរៀបចំស្ថាប័នសម្រាប់ការចរចា) នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌដែលចែងថា "គណៈកម្មាធិការចរចាពាណិជ្ជកម្មអាស៊ាន-ចិន (ACFTA) ដែលបានបង្កើតឡើង នឹងបន្តអនុវត្តកម្មវិធីនៃការចរចាដែលមានចែងក្នុងកិច្ចព្រមព្រៀង"

**ដោយកត់សម្គាល់ឃើញថា** កិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេវា និងកិច្ចព្រមព្រៀងវិនិយោគ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌដែលបានបញ្ចប់ការចរចា និងបានចុះហត្ថលេខាជាបន្តបន្ទាប់គ្នានៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០៤ ថ្ងៃទី១៤ ខែមករា ឆ្នាំ២០០៧ និងថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០៩ និងរក្សាទុកមាត្រាស្តីពី បទបញ្ញត្តិស្ថាប័ននៃកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញ និងកិច្ចព្រមព្រៀងវិនិយោគទាំងពីរបានចែងថា "ក្នុងការរង់ចាំការបង្កើតអង្គភាពអចិន្ត្រៃយ៍ រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានក្រសួងពាណិជ្ជកម្មចិន (AEM-MOFCOM) ដែលបានគាំទ្រ និងជ្រោមជ្រែងដោយ SEOM-MOFCOM នឹងត្រួតពិនិត្យ សម្របសម្រួល និងពិនិត្យឡើងវិញនូវការអនុវត្តនៃកិច្ចព្រមព្រៀងនេះ"

**ដោយរំលឹកឡើងវិញ** សេចក្តីប្រកាសព័ត៌មានរួមរបស់រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន-ចិន នាកិច្ចប្រជុំពិគ្រោះយោបល់លើកទី១០ (The 10th AEM-MOFCOM) ដែលកំណត់ថា "រដ្ឋមន្ត្រីទាំងអស់បានយល់ព្រមឲ្យបង្កើតគណៈកម្មាធិការរួមគ្នាតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន (ACFTA-JC) ជំនួសឲ្យគណៈកម្មាធិការចរចាពាណិជ្ជកម្មអាស៊ាន-ចិន (ACTNC)។ កិច្ចការចម្បងរបស់ JC នឹងរួមបញ្ចូលការត្រួតពិនិត្យ គ្រប់គ្រង សម្របសម្រួល និងពិនិត្យឡើងវិញលើការអនុវត្តកិច្ចព្រមព្រៀង"

*បកប្រែក្រៅផ្លូវការ*

**ដោយស្វះស្វែង** បង្កើតបទបញ្ញត្តិស្ថាប័នអចិន្ត្រៃយ៍ជាង ដើម្បីត្រួតពិនិត្យ សម្របសម្រួល និងពិនិត្យឡើងវិញ នូវការអនុវត្តកិច្ចព្រមព្រៀងក្របខ័ណ្ឌរួមទាំងកិច្ចព្រមព្រៀងដទៃទៀត ដែលបានចុះហត្ថលេខាផងដែរ អនុលោមតាមកិច្ចព្រមព្រៀងក្របខ័ណ្ឌ

**ដោយទទួលស្គាល់** តម្រូវការក្នុងការបង្កើតចំណងទាក់ទងយ៉ាងជាក់លាក់តាមផ្លូវច្បាប់ រវាងកិច្ចព្រមព្រៀងក្របខ័ណ្ឌ និងកិច្ចព្រមព្រៀងផ្សេងៗទៀតដែលបានចរចា និងបានចុះហត្ថលេខាដោយផ្អែកលើមូលដ្ឋាន នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌនេះ និង

**ដោយកត់សម្គាល់** ឃើញថាមាត្រា១៤ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌ បានចែងថាការកែប្រែនានា ត្រូវមានការយល់ព្រមទៅវិញទៅមកជាលាយលក្ខណ៍អក្សរពីបណ្តាភាគី

**បានព្រមព្រៀងដូចខាងក្រោម៖**

## មាត្រា ១
## វិសោធនកម្មលើមាត្រា១២ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌ

មាត្រា១២ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌត្រូវលុបចោល និងដាក់ជំនួសទាំងស្រុងដោយមាត្រា១២ថ្មី ដែលមានចែងដូចខាងក្រោម៖

"មាត្រា ១២
បទបញ្ញត្តិស្ថាប័ន

១. បណ្តាភាគី តាមរយៈនេះបង្កើតគណៈកម្មាធិការរួមតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន (ACFTA-JC) ជាអង្គភាពអចិន្ត្រៃយ៍ជួយដល់ AEM-MOFCOM ក្នុងការធានាប្រសិទ្ធភាពប្រតិបត្តិការ និងការអនុវត្តកិច្ចព្រមព្រៀងនេះព្រមទាំងកិច្ចព្រមព្រៀង និងឧបករណ៍ស្របច្បាប់ផ្សេងៗទៀត ដែលបានចុះហត្ថលេខា ឬ និងត្រូវចុះហត្ថលេខាក្រោមកិច្ចព្រមព្រៀងនេះ។

២. តួនាទីរបស់គណៈកម្មាធិការរួមគឺ៖

(ក) ពិនិត្យឡើងវិញតាមដាន ត្រួតពិនិត្យ និងសម្របសម្រួលការអនុវត្ត និងប្រតិបត្តិការនៃកិច្ចព្រមព្រៀងនេះ និងឧបករណ៍ពេញលក្ខណៈច្បាប់ ទាំងអស់ដែលស្ថិតក្រោមកិច្ចព្រមព្រៀងនេះ

(ខ) ពិចារណា និងផ្តល់អនុសាសន៍ទៅឲ្យ AEM-MOFCOM រាល់ការធ្វើវិសោធនកម្មកិច្ចព្រមព្រៀងនេះ និងឧបករណ៍ពេញលក្ខណៈច្បាប់នានា ដែលស្ថិតក្រោមកិច្ចព្រមព្រៀងនេះ

(គ) ចរចាវិសោធនកម្ម ឬបញ្ហាដែលកើតមានពីប្រតិបត្តិការនៃកិច្ចព្រមព្រៀងនេះ និងឧបករណ៍ពេញលក្ខណៈច្បាប់នានា ដែលស្ថិតក្រោមកិច្ចព្រមព្រៀងនេះ

*បកប្រែក្រៅផ្លូវការ*

(ឃ) គ្រប់គ្រង និងសម្របសម្រួល ការងារនៃអង្គភាពសាខាដែលត្រូវបង្កើតក្រោមកិច្ចព្រមព្រៀងនេះ និងរាល់ឧបករណ៍ពេញលក្ខណៈច្បាប់ដែលស្ថិតក្រោមកិច្ចព្រមព្រៀងនេះ

(ង) ព្រមទទួលយកបើសមរម្យ ការសម្រេច និងអនុសាសន៍នានារបស់អង្គភាពសាខា ដែលត្រូវបានបង្កើត ឬត្រូវបង្កើត អនុលោមតាមកិច្ចព្រមព្រៀងនេះ រាល់ឧបករណ៍ពេញលក្ខណៈច្បាប់ ដែលស្ថិតក្រោមកិច្ចព្រមព្រៀងនេះ

(ច) ពិចារណាបញ្ហានានា ដែលអាចប៉ះពាល់ប្រតិបត្តិការនៃកិច្ចព្រមព្រៀងនេះ និងរាល់ឧបករណ៍ពេញលក្ខណៈច្បាប់ដទៃទៀត ដែលស្ថិតក្រោមកិច្ចព្រមព្រៀងនេះ ឬដែលប្រគល់ឲ្យគណៈកម្មាធិការរួមដោយបណ្តាភាគី និង

(ឆ) អនុវត្តរាល់តួនាទីដទៃទៀត ដូចដែលបណ្តាភាគីយល់ព្រម។

៣. ដើម្បីជាជំនួយក្នុងការបំពេញតួនាទី គណៈកម្មាធិការរួមអាចបង្កើតអង្គភាពរងបន្ថែមបាន រួមទាំងអង្គភាពបណ្តោះអាសន្នសម្រាប់កិច្ចការដោយឡែក (ad hoc bodies) និងប្រគល់ឲ្យអង្គភាពនោះនូវកិច្ចការលើបញ្ហាជាក់លាក់ ឬផ្ទេរការទទួលខុសត្រូវទៅអង្គភាពរង ដែលត្រូវបានបង្កើតដោយអនុលោមតាមកិច្ចព្រមព្រៀងនេះ និងរាល់ឧបករណ៍ពេញលក្ខណៈច្បាប់ ដែលស្ថិតក្រោមកិច្ចព្រមព្រៀងនេះ។

៤. គណៈកម្មាធិការរួមត្រូវកោះប្រជុំយ៉ាងតិចពីរដងក្នុងមួយឆ្នាំ ឬពេលណាមួយដែលគិតថាចាំបាច់។ អ្នកសម្របសម្រួលសម្រាប់ប្រទេសសមាជិកអាស៊ាន ផ្នែកសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយជាមួយប្រទេសចិន និងប្រទេសចិន ត្រូវធ្វើជាសហប្រធានសម្រាប់គណៈកម្មាធិការរួម។ កិច្ចប្រជុំគណៈកម្មាធិការរួមត្រូវធ្វើឡើងដោយផ្លាស់ប្តូរវេនគ្នារវាងប្រទេសសមាជិកអាស៊ាន និងប្រទេសចិន។ លេខាធិការដ្ឋានអាស៊ាន និងក្រសួងពាណិជ្ជកម្មចិន (MOFCOM) ត្រូវផ្តល់ការទ្រទ្រង់លេខាធិការដ្ឋានចាំបាច់ដល់គណៈកម្មាធិការរួម។

៥. គណៈកម្មាធិការរួមត្រូវរាយការណ៍ជាប្រចាំទៅឲ្យកិច្ចប្រជុំពិគ្រោះយោបល់ AEM-MOFCOM តាមរយៈកិច្ចប្រជុំឧត្តមមន្ត្រីសេដ្ឋកិច្ចរបស់ខ្លួន។"

## មាត្រា ២
## ការតម្កល់ទុក

សម្រាប់រដ្ឋសមាជិកអាស៊ាន ពិធីសារនេះត្រូវបានតម្កល់ទុកនៅអគ្គលេខាធិការដ្ឋានអាស៊ាន ដែលជាអ្នកត្រូវបញ្ជូនជាបន្ទាន់ នូវច្បាប់ដែលបានបញ្ជាក់ត្រឹមត្រូវដល់សមាជិកនីមួយៗ។

*បកប្រែក្រៅផ្លូវការ*

## មាត្រា ៣
## ការចូលជាធរមាន

១. ពិធីសារនេះនឹងចូលជាធរមានចាប់ពីថ្ងៃ០១ ខែមករា ឆ្នាំ២០១៣។

២. បណ្តាភាគីនឹងទទួលរ៉ាប់រងបំពេញរាល់នីតិវិធីក្នុងស្រុករបស់ខ្លួន សម្រាប់ការចូលជាធរមាននៃពិធីសារនេះឲ្យបានមុនថ្ងៃ០១ ខែមករា ឆ្នាំ២០១៣។

៣. ភាគីនឹង អាស្រ័យលើការបំពេញនីតិវិធីក្នុងស្រុករបស់ខ្លួនសម្រាប់ការចូលជាធរមាននៃពិធីសារនេះ ជូនដំណឹងដល់បណ្តាភាគីជាលាយលក្ខណ៍អក្សរ។

៤. ក្នុងករណីដែលភាគីណាមួយមិនអាចបញ្ចប់នីតិវិធីក្នុងស្រុករបស់ខ្លួន សម្រាប់ការចូលជាធរមាននៃពិធីសារនេះត្រឹមថ្ងៃ០១ ខែមករា ឆ្នាំ២០១៣ សិទ្ធិ និងកាតព្វកិច្ចទាំងឡាយរបស់ភាគីនោះក្រោមពិធីសារនេះ នឹងចាប់ផ្តើមនៅកាលបរិច្ឆេទនៃការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅភាគីទាំងអស់ថាភាគីនោះបានបញ្ចប់នីតិវិធីក្នុងស្រុករបស់ខ្លួន សម្រាប់ការចូលជាធរមាននៃពិធីសារនេះ។

**ដើម្បីជាសក្ខីភាព** ហត្ថលេខីខាងក្រោមដែលបានទទួលសិទ្ធិប្រទានពេញលេញពីរដ្ឋាភិបាលរៀងៗខ្លួន បានចុះហត្ថលេខាលើពិធីសារទី៣ ដើម្បីធ្វើវិសោធនកម្មកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពី សហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋប្រជាមានិតចិន។

ធ្វើនៅភ្នំពេញ ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំពីរពាន់ដប់ពីរ ជាពីរច្បាប់ជាភាសាអង់គ្លេស។

**សម្រាប់ប្រ៊ុយណេដារូសាឡាំ**
ហត្ថលេខា

លីម យុកសេង
រដ្ឋមន្ត្រីទី២ កិច្ចការអន្តរជាតិ និងពាណិជ្ជកម្ម

**សម្រាប់រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតចិន**
ហត្ថលេខា

ចេង ឌីមីង
រដ្ឋមន្ត្រីពាណិជ្ជកម្ម

**សម្រាប់ព្រះរាជាណាចក្រកម្ពុជា**
ហត្ថលេខា

ចម ប្រសិទ្ធ
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីពាណិជ្ជកម្ម

*បកប្រែក្រៅផ្លូវការ*

**សម្រាប់សាធារណរដ្ឋឥណ្ឌូនេស៊ី**

ហត្ថលេខា

ហ្គីតា អ៊ីរ៉ាវ៉ាន់ វីយ៉ាវ៉ាន់

រដ្ឋមន្ត្រីពាណិជ្ជកម្ម

**សម្រាប់សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ**

ហត្ថលេខា

ណាម វីយ៉ាកេត

រដ្ឋមន្ត្រី ឧស្សាហកម្ម និងពាណិជ្ជកម្ម

**សម្រាប់ម៉ាឡេស៊ី**

ហត្ថលេខា

ម៉ូស្តាប៉ា មហាម៉េត

រដ្ឋមន្ត្រីពាណិជ្ជកម្មអន្តរជាតិ និងឧស្សាហកម្ម

**សម្រាប់សហភាពមីយ៉ាន់ម៉ា**

ហត្ថលេខា

កាន ហ្ស

រដ្ឋមន្ត្រីសហភាព សម្រាប់ផែនការអន្តរជាតិ និងការអភិវឌ្ឍសេដ្ឋកិច្ច

**សម្រាប់សាធារណរដ្ឋហ្វីលីពីន**

ហត្ថលេខា

គ្រីហ្គូរី អេល ដូមីងហ្គូ

លេខាធិការ ពាណិជ្ជកម្ម និងឧស្សាហកម្ម

ព្រះរាជាណាចក្រកម្ពុជា

*Kingdom of Cambodia*

រាជរដ្ឋាភិបាល

*Royal Government*

ជាតិ សាសនា ព្រះមហាក្សត្រ

*Nation Religion King*

Nº 102.D.F.P

Phnom Penh, October 02, 2012

**DELEGATION OF FULL POWER**

- Having seen the Constitution of the Kingdom of Cambodia
- Having seen the Royal Decree No. NS/RKT/0908/1055 dated September 25, 2008 on the composition of Royal Government of Cambodia
- Having seen the Royal Decree No. 02/NS/94 dated July 20, 1994 on the organization and the functioning of the Council of Ministers
- Referring to the request of the Minister of Economy and Finance

**THE ROYAL GOVERNMENT OF CAMBODIA**

Delegates herewith full power to **H.E CHAM PRASIDH**, Senior Minister, Minister of Commerce and Minister in charge of the ASEAN Economic Minister, to sign, on behalf of the Royal Government of Cambodia, the Third Protocol to Amend the Framework Agreement on Comprehensive Economic Co-operation between the Association of Southeast Asian Nations and the People's Republic of China, the Protocol to Incorporate Sanitary and Phytosanitary Measures and Technical Barriers to Trade into the Agreement on Trade in Goods of the Framework Agreement on Comprehensive Economic Cooperation between the Association of Southeast Asian Nations and the People's Republic of China.

This power includes the power of delegation.

In witness whereof, the undersigned, Samdech Akka Moha Sena Padei Techo **HUN SEN**, Prime Minister of the Kingdom of Cambodia, with full power duly entrusted to him, has signed this delegation of full power.

**PRIME MINISTER**

**Samdech Akka Moha Sena Padei Techo HUN SEN**

# THIRD PROTOCOL TO AMEND THE FRAMEWORK AGREEMENT ON COMPREHENSIVE ECONOMIC CO-OPERATION BETWEEN THE ASSOCIATION OF SOUTHEAST ASIAN NATIONS AND THE PEOPLE'S REPUBLIC OF CHINA

The Governments of Brunei Darussalam, the Kingdom of Cambodia, the Republic of Indonesia, the Lao People's Democratic Republic, Malaysia, the Republic of the Union of Myanmar, the Republic of the Philippines, the Republic of Singapore, the Kingdom of Thailand, the Socialist Republic of Viet Nam, Member States of the Association of Southeast Asian Nations (hereinafter referred to collectively as "ASEAN" or "ASEAN Member States" or singularly as "ASEAN Member State") and the Government of the People's Republic of China (hereinafter referred to as "China"), (hereinafter referred to collectively as "Parties" and singularly as "Party"),

**RECALLING** the Framework Agreement on Comprehensive Economic Co-operation between the Association of Southeast Asian Nations and the People's Republic of China (hereinafter referred to as "the Framework Agreement") signed on 4 November 2002 and that paragraph 1 of Article 12 (Institutional Arrangements for the Negotiations) of the Framework Agreement provides that "the ASEAN-China Trade Negotiation Committee (ACTNC) that has been established shall continue to carry out the program of negotiations set out in this Agreement";

**NOTING** that the Agreement on Trade in Goods, Agreement on Trade in Services and the Agreement on Investment of the Framework Agreement have been concluded and signed on 29 November 2004, 14 January 2007 and 15 August 2009, respectively, and that the Institutional Arrangement Article of both the Agreement on Trade in Goods and the

CERTIFIED COPY DEPUTY SECRETARY GENERAL, THE ASEAN SECRETARIAT

Agreement on Investment provide that "pending the establishment of a permanent body, the AEM-MOFCOM, supported and assisted by the SEOM-MOFCOM, shall oversee, supervise, coordinate and review the implementation of this Agreement";

**RECALLING** that the Joint Media Statement of the 10th AEM-MOFCOM Consultations provides that "the Ministers endorsed the establishment of the ASEAN-China FTA Joint Committee (ACFTA-JC) in place of the ACTNC. The ACFTA-JC's main tasks will include overseeing, supervising, coordinating and reviewing the implementation of the Agreement";

**SEEKING** to establish a more permanent institutional arrangement for overseeing, supervising, coordinating and reviewing the implementation of the Framework Agreement as well as any other agreements concluded in accordance with the Framework Agreement;

**RECOGNISING** the need to establish an explicit legal linkage between the Framework Agreement and the various Agreements negotiated and signed on the basis of the said Framework Agreement; and

**NOTING** that Article 14 of the Framework Agreement provides for any amendments thereto to be mutually agreed upon in writing by the Parties,

**HAVE AGREED AS FOLLOWS:**

**Article 1**
**Amendment of Article 12 of the Framework Agreement**

Article 12 of the Framework Agreement shall be deleted and substituted entirely by a new Article 12 as set out below:



CERTIFIED COPY
DEPUTY SECRETARY GENERAL ASEAN SECRETARIAT

## "ARTICLE 12
## Institutional Provisions

1. The Parties hereby establish the ASEAN-China Free Trade Area Joint Committee (ACFTA-JC) as the permanent body to assist the ASEAN Economic Ministers and the Minister of Commerce of China (hereinafter referred to as "AEM-MOFCOM") in ensuring the effective operation and implementation of this Agreement and any other Agreements/legal instruments concluded or to be concluded under this Agreement.

2. The functions of the ACFTA-JC shall be to:

(a) review, monitor, oversee, supervise and coordinate the implementation and operation of this Agreement and all legal instruments under it;

(b) consider and recommend to the AEM-MOFCOM any amendments to this Agreement and all legal instruments under it;

(c) negotiate amendments to or any matter arising from the operation of this Agreement and all legal instruments under it;

(d) supervise and co-ordinate the work of subsidiary bodies to be established under this Agreement and all legal instruments under it;

(e) adopt, where appropriate, decisions and recommendations of subsidiary bodies established or to be established pursuant to this Agreement and all legal instruments under it;

(f) consider any other matter that may affect the operation of this Agreement and all legal instruments under it or that is entrusted to the ACFTA-JC by the Parties; and

(g) carry out any other functions as the Parties may agree.

3. To assist in the fulfillment of its functions, the ACFTA-JC may establish additional subsidiary bodies, including *ad hoc* bodies, and assign them with tasks on specific matters, or delegate its responsibilities to any subsidiary body established pursuant to this Agreement or any legal instruments under it.

4. The ACFTA-JC shall convene the meetings at least twice a year or as and when it deems necessary. The ASEAN Country Coordinator for comprehensive economic cooperation with China, and China, shall assume the co-chairmanship of the ACFTA-JC. The ACFTA-JC meetings shall be held alternately in an ASEAN Member State and China. The ASEAN Secretariat and the Ministry of Commerce (MOFCOM) of China shall provide the ACFTA-JC with the necessary secretariat support.

5. The ACFTA-JC shall regularly report to the AEM-MOFCOM Consultations, through the meetings of their Senior Economic Officials."

**Article 2**
**Depositary**

For the ASEAN Member States, this Protocol shall be deposited with the Secretary-General of ASEAN, who shall promptly furnish a certified copy thereof to each ASEAN Member State.

**Article 3**
**Entry into Force**

1. This Protocol shall enter into force on 1 January 2013.

2. The Parties shall undertake to complete their internal procedures for the entry into force of this Protocol prior to 1 January 2013.

3. A Party shall, upon the completion of its internal procedures for the entry into force of this Protocol, notify all the other Parties in writing.

4. Where a Party is unable to complete its internal procedures for the entry into force of this Protocol by 1 January 2013, the rights and obligations of that Party under this Protocol shall commence on the date of the Party's written notification to all the other Parties that it has completed its internal procedure for the entry into force of this Protocol.

**IN WITNESS WHEREOF**, the undersigned being duly authorised by their respective Governments, have signed this Third Protocol to Amend the Framework Agreement on Comprehensive Economic Co-operation between the Association of Southeast Asian Nations and the People's Republic of China.

**DONE** at Phnom Penh, Cambodia, this 19 November in the Year Two Thousand and Twelve, in duplicate copies in the English language.

For Brunei Darussalam:

**LIM JOCK SENG**
Second Minister of Foreign Affairs and Trade

For the People's Republic of China:

**CHEN DEMING**
Minister of Commerce

For the Kingdom of Cambodia:

**CHAM PRASIDH**
Senior Minister and Minister of Commerce

For the Republic of Indonesia:

**GITA IRAWAN WIRJAWAN**
Minister of Trade

For the Lao People's Democratic Republic:

**NAM VIYAKETH**
Minister of Industry and Commerce

For Malaysia:

**MUSTAPA MOHAMED**
Minister of International Trade and Industry

For the Republic of the Union of Myanmar:

**KAN ZAW**
Union Minister for National Planning and Economic Development

For the Republic of the Philippines:

**GREGORY L. DOMINGO**
Secretary of Trade and Industry

For the Republic of Singapore:

**LIM HNG KIANG**
Minister for Trade and Industry

For the Kingdom of Thailand:

**BOONSONG TERIYAPIROM**
Minister of Commerce

For the Socialist Republic of Viet Nam:

**VU HUY HOANG**
Minister of Industry and Trade



CERTIFIED COPY
DEPUTY SECRETARY GENERAL, THE ASEAN SECRETARIAT

*បកប្រែក្រៅផ្លូវការ*

# ពិធីសារបញ្ចូលវិធានការអនាម័យ និងភូតគាមអនាម័យ និងរបាំងបច្ចេកទេសពាណិជ្ជកម្មទៅក្នុង កិច្ចព្រមព្រៀងទំនិញ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពី សហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាង សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋប្រជាមានិតចិន

៙៙*៙៙

រដ្ឋាភិបាល នៃប្រទេសប្រ៊ុយណេដារូសាឡាំ ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋឥណ្ឌូនេស៊ី សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ ម៉ាឡេស៊ី សហភាពមីយ៉ាន់ម៉ា សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសិង្ហបុរី ព្រះរាជាណាចក្រថៃ និងសាធារណរដ្ឋសង្គមនិយមវៀតណាម បណ្តារដ្ឋសមាជិកនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (ទាំងអស់ហៅកាត់រួមគ្នាថា "អាស៊ាន" ឬ "បណ្តារដ្ឋសមាជិកអាស៊ាន" ឬរដ្ឋនីមួយៗហៅថាប្រទេសសមាជិកអាស៊ាន និងសាធារណរដ្ឋប្រជាមានិតចិន ("ចិន") ដែលខាងក្រោមនេះហៅថា "បណ្តាភាគី" ឬរៀងៗខ្លួនសំដៅលើរដ្ឋសមាជិកអាស៊ាន ឬចិនហៅថា "ភាគី"

ដោយរំលឹកឡើងវិញ កិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌ ស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយ រវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋប្រជាមានិតចិន (ដែលខាងក្រោមនេះហៅថា "កិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញ") ដែលបានចុះហត្ថលេខាដោយរដ្ឋមន្ត្រីសេដ្ឋកិច្ច នៃបណ្តារដ្ឋសមាជិកអាស៊ាន និងចិន នាថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០៤ នៅទីក្រុងវៀងច័ន្ទ សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ និងពិធីសារពាក់ព័ន្ធរបស់កិច្ចព្រមព្រៀងនេះ

ដោយទទួលស្គាល់ តម្រូវការចំណងទាក់ទងសេដ្ឋកិច្ចឲ្យកាន់តែស៊ីជម្រៅរវាងអាស៊ាន-ចិន ដោយកាត់បន្ថយជាអតិបរិមារបាំងពាណិជ្ជកម្ម ប៉ុន្តែធានាការការពារជីវិត និងសុខភាពមនុស្ស សត្វឬរុក្ខជាតិក្នុងដែនដីរៀងៗខ្លួន

ដោយជឿជាក់ថា កិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញដែលមានគុណភាពខ្ពស់ អាចជួយសម្រួលនិងធ្វើឱ្យប្រសើរឡើងនូវការអនុវត្ត និងការប្រើប្រាស់ពន្ធអនុគ្រោះដ៏មានប្រសិទ្ធិភាព ក្រោមតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន

ដោយកត់សម្គាល់ឃើញថា មាត្រា១៨ នៃកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញ ចែងថាកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញ "អាចរួមបញ្ចូលគ្រប់ឧបករណ៍ពេញលក្ខណៈច្បាប់ទាំងអស់ ដែលឯកភាពគ្នាស្របតាមកិច្ចព្រមព្រៀងនេះ"

*បកប្រែក្រៅផ្លូវការ*

ដោយស្វះស្វែង ដើម្បីដាក់បញ្ចូលទៅក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញ មាត្រាដ៏មានសារៈសំខាន់នានា លើការអនុវត្តរបាំងបច្ចេកទេសពាណិជ្ជកម្ម (ដែលខាងក្រោមនេះហៅកាត់ថា"TBT") វិធានការអនាម័យនិងភូតគាមអនាម័យ (ដែលខាងក្រោមនេះហៅកាត់ថា"SPS")

បានព្រមព្រៀងដូចខាងក្រោម៖

## ជំពូក ១
## របាំងបច្ចេកទេសពាណិជ្ជកម្ម

### មាត្រា ១
### គោលបំណង

គោលបំណងនៃជំពូកនេះគឺ៖

ក. ធ្វើការសម្របសម្រួល និងជំរុញការធ្វើពាណិជ្ជកម្ម ទំនិញនៅក្នុងចំណោមភាគីទាំងអស់ដោយធ្វើឲ្យប្រាកដថា បញ្ញត្តិបច្ចេកទេស ស្តង់ដារ និងនីតិវិធីវាយតម្លៃភាពអនុលោម មិនបង្កើតជារបាំងដែលមិនចាំបាច់ចំពោះពាណិជ្ជកម្ម

ខ. ពង្រឹងកិច្ចសហប្រតិបត្តិការ រួមមានការផ្លាស់ប្តូរព័ត៌មានពាក់ព័ន្ធទៅនឹង ការរៀបចំការអនុម័ត និងការអនុវត្ត ស្តង់ដារ បញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតម្លៃភាពអនុលោម

គ. ជំរុញការយោគយល់គ្នាទៅវិញទៅមក អំពីស្តង់ដារ បញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតម្លៃភាព អនុលោមរបស់ភាគីនីមួយៗ

ឃ. ធ្វើដំណោះស្រាយឲ្យមានប្រសិទ្ធភាព លើបញ្ហាទាំងឡាយណាដែលកើតចេញមកពីពាណិជ្ជកម្ម រវាងភាគីនីមួយៗ។

### មាត្រា ២
### វិសាលភាព

ជំពូកនេះ ត្រូវអនុវត្តទៅលើរាល់គ្រប់ បញ្ញត្តិបច្ចេកទេស ស្តង់ដារ និងនីតិវិធីវាយតម្លៃភាពអនុលោមរបស់ភាគីនីមួយៗ ដែលអាចមានឥទ្ធិពលដោយផ្ទាល់ ឬមិនផ្ទាល់ទៅលើការធ្វើពាណិជ្ជកម្មទំនិញរវាងភាគីទាំងសងខាង។ ជំពូកនេះត្រូវលើកលែងលើ៖

ក. វិធានការអនាម័យ និងភូតគាមនអម័យ ដែលមានចែងនៅក្នុងជំពូក២ នៃកិច្ចព្រមព្រៀងនេះ និង

ខ. ការបញ្ជាទិញយថាប្រភេទគ្រប់ប្រភេទ ដែលរៀបចំដោយអង្គភាពរដ្ឋ សម្រាប់ផលិតកម្ម ឬការតម្រូវការប្រើប្រាស់របស់អង្គភាពរដ្ឋ។

*បកប្រែក្រៅផ្លូវការ*

## មាត្រា ៣
## និយមន័យ

សម្រាប់គោលបំណងនៃពិធីការនេះ និយមន័យដែលមាននៅក្នុងឧបសម្ព័ន្ធ១ ភ្ជាប់ទៅនឹងកិច្ចព្រមព្រៀង ស្តីពីរបាំងបច្ចេកទេសចំពោះពាណិជ្ជកម្ម (ដែលខាងក្រោមនេះហៅថា "កិច្ចព្រមព្រៀង TBT") នៅក្នុងឧបសម្ព័ន្ធ១ក ភ្ជាប់ទៅនឹងកិច្ចព្រមព្រៀង WTO ត្រូវយកមកអនុវត្ត។

## មាត្រា ៤
## ការអះអាងនៃកិច្ចព្រមព្រៀង TBT

ភាគីនីមួយៗអះអាងពីសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួន ដោយគោរពគ្នាទៅវិញទៅមកនៅក្នុងកិច្ចព្រមព្រៀង TBT នេះ។

## មាត្រា ៥
## បទប្បញ្ញត្តិបច្ចេកទេស

១. បើសិនមានស្តង់ដារអន្តរជាតិពាក់ព័ន្ធ ឬការពាក់ព័ន្ធទាំងស្រុងនៃស្តង់ដារទាំងនោះ នឹងកើតមានឡើង ភាគីនីមួយៗ ត្រូវតែយកស្តង់ដារទាំងនោះមកប្រើប្រាស់ ឬផ្នែកណាមួយដែលពាក់ព័ន្ធ ដើម្បីធ្វើជាមូលដ្ឋានសម្រាប់ជាបញ្ញត្តិបច្ចេកទេសរបស់ខ្លួន លើកលែងតែស្តង់ដារអន្តរជាតិទាំងនោះ ឬភាគពាក់ព័ន្ធទាំងនោះ ជាមធ្យោបាយមួយមិនសក្តិសិទ្ធិ ឬមិនសមស្របសម្រាប់ការបំពេញ នៃគោលដៅតាមផ្លូវច្បាប់ ដែលត្រូវការដូចជាក្នុងករណីដោយសារកត្តាអាកាសធាតុ ឬភូមិសាស្ត្រជាមូលដ្ឋាន ឬបញ្ហាបច្ចេកវិទ្យាជាមូលដ្ឋានជាដើម។

២. ភាគីនីមួយៗត្រូវតែផ្តល់ការពិចារណាជាវិជ្ជមាន លើការទទួលយកនូវកម្រិតស្មើគ្នា បញ្ញត្តិបច្ចេកទេសរបស់ភាគីមួយទៀត ទោះបីជាបញ្ញត្តិទាំងនោះខុសគ្នាពីរបស់ខ្លួនក៏ដោយ ដែលបានផ្តល់មក គឺបញ្ជាក់ថាបញ្ញត្តិទាំងអស់នោះបានបំពេញគ្រប់គ្រាន់ ទៅនឹងគោលដៅនៃបញ្ញត្តិរបស់ខ្លួនផ្ទាល់។

៣. បើភាគីណាមួយ មិនព្រមទទួលយកបញ្ញត្តិបច្ចេកទេសណាមួយ របស់ភាគីមួយទៀតមានកម្រិតស្មើទៅនឹងរបស់ខ្លួនផ្ទាល់នោះ ត្រូវពន្យល់ហេតុផល អំពីការសម្រេចចិត្តរបស់ខ្លួននៅពេលដែលមានការស្នើសុំពីភាគីម្ខាងទៀត ។

## មាត្រា ៦
## ស្តង់ដារ

១. ដោយគោរពទៅតាមការរៀបចំការអនុម័ត និងការអនុវត្តស្តង់ដារ ភាគីនីមួយៗត្រូវធានាថា អង្គភាពស្តង់ដារមួយ ឬច្រើនរបស់ខ្លួនទទួលយក និងអនុលោមតាមឧបសម្ព័ន្ធ៣ នៃកិច្ចព្រមព្រៀង TBT។

*បកប្រែក្រៅផ្លូវការ*

២. ភាគីនីមួយៗត្រូវលើកទឹកចិត្តអង្គភាពស្តង់ដារមួយ ឬច្រើននៅក្នុងដែនដីរបស់ខ្លួន ធ្វើកិច្ចសហការជាមួយអង្គភាពស្តង់ដារមួយ ឬច្រើនរបស់ភាគីផ្សេងទៀត។ កិច្ចសហការនេះគឺត្រូវមាន ប៉ុន្តែមិនកម្រិតទៅលើ៖

ក. ការផ្លាស់ប្តូរព័ត៌មានលើផ្នែកស្តង់ដារ

ខ. ការផ្លាស់ប្តូរព័ត៌មានពាក់ព័ន្ធទៅនឹងស្តង់ដារបង្កើតនីតិវិធីនានា និង

គ. ការសហការក្នុងការងាររបស់អង្គភាពស្តង់ដារអន្តរជាតិនៅក្នុងផ្នែកដែលមានផលប្រយោជន៍ទៅវិញទៅមក ។

## មាត្រា ៧
## នីតិវិធីវាយតម្លៃភាពអនុលោម

១. ភាគីនីមួយៗត្រូវតែរកវិធី ដើម្បីធ្វើឲ្យប្រសើរឡើងអំពីការទទួលយកនូវលទ្ធផលនៃនីតិវិធីវាយតម្លៃភាពអនុលោម ដែលបានអនុវត្តក្នុងដែនដីនៃភាគីមួយទៀត ដោយបង្ហាញឲ្យឃើញនូវការរីកចំរើនពីសមត្ថភាព និងការធានានូវប្រសិទ្ធភាពតម្លៃនៃការវាយតម្លៃភាពអនុលោម។

២. គ្រប់ភាគីទាំងអស់ទទួលស្គាល់ថា មានវិធីសាស្ត្រជាច្រើន ដើម្បីសម្របសម្រួលអំពីការទទួលយកនីតិវិធីវាយតម្លៃភាពអនុលោម និងលទ្ធផលចេញពីនោះ។

៣. គ្រប់ភាគីទាំងអស់ឯកភាពគ្នាក្នុងការផ្លាស់ប្តូរព័ត៌មានទៅវិញទៅមក អំពីនីតិវិធីវាយតម្លៃភាពអនុលោមដោយរួមបញ្ចូលទាំងការធ្វើតេស្ត ការធ្វើអធិការកិច្ច ការបញ្ជាក់វិញ្ញាបនប័ត្រ ការវាយតម្លៃទទួលស្គាល់ និងមាត្រាសាស្ត្រ ដោយបង្ហាញទៅតាមការចេចារលើកិច្ចព្រមព្រៀង សហប្រតិបត្តិការនៅក្នុងផ្នែកនីតិវិធីវាយតម្លៃភាពអនុលោម ឲ្យសមស្របទៅតាមកិច្ចព្រមព្រៀង TBT និងបទបញ្ញត្តិក្នុងប្រទេសរបស់ភាគីទាំងអស់នោះ។

៤. ពេលដែលមានកិច្ចសហប្រតិបត្តិការក្នុងការវាយតម្លៃភាពអនុលោម ភាគីទាំងអស់ត្រូវតែធ្វើការពិចារណាអំពីការចូលរួមរបស់ពួកគេក្នុងអង្គការតំបន់ និង/ឬ អង្គការអន្តរជាតិ ដែលអាចអនុវត្តបានដូចជាវេទិកាអន្តរជាតិស្តីពីការវាយតម្លៃទទួលស្គាល់ (International Accreditation Forum-IAF) កិច្ចសហប្រតិបត្តិការនៃការវាយតម្លៃ ទទួលស្គាល់មន្ទីរពិសោធន៍អន្តរជាតិ (International Laboratory Accreditation Cooperation-ILAC) ការិយាល័យទំនាក់ទំនងអន្តរជាតិសម្រាប់ទម្ងន់ និងរង្វាស់រង្វាល់ (International Bureau of Weights and Measures-BIMP) អង្គការអន្តរជាតិនៃមាត្រាសាស្ត្រ (International Organization of legal Metrology-OIML) និងអង្គការអន្តរជាតិពាក់ពន្ធ័ផ្សេងៗទៀត។

*បកប្រែក្រៅផ្លូវការ*

៥. ភាគីទាំងអស់ឯកភាពគ្នា លើកទឹកចិត្តដល់អង្គភាពវាយតម្លៃភាពអនុលោមរបស់ពួកគេក្នុងការអនុវត្តការងារឲ្យបានកាន់តែមានភាពស្និទស្នាល ដោយបង្ហាញឲ្យឃើញពីការជួយសម្របសម្រួលអំពីការទទួលយកលទ្ធផល នៃការវាយតម្លៃភាពអនុលោមរវាងភាគីទាំងអស់។

៦. តាមការស្នើសុំពីភាគីមួយទៀត ភាគីមួយត្រូវតែផ្តល់នូវហេតុផលរបស់ខ្លួន សម្រាប់ការមិនទទួលយកនូវលទ្ធផល នៃនីតិវិធីវាយតម្លៃភាពអនុលោមណាមួយដែលបានអនុវត្តនៅក្នុងដែនដីនៃភាគីមួយទៀតនោះ។

## មាត្រា ៨
## តម្លាភាព

១. ភាគីនីមួយៗអះអាងនូវការប្តេជ្ញារបស់ខ្លួនដើម្បីធានាថា ព័ត៌មានអំពីស្តង់ដារ បញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតម្លៃភាពអនុលោមដែលនឹងស្នើសុំថ្មី ឬការកែប្រែត្រូវតែអាចរកបានដោយឲ្យស្របទៅតាមការតម្រូវពាក់ព័ន្ធទាំងអស់នៃកិច្ចព្រមព្រៀង TBT។

២. ភាគីនីមួយៗ ត្រូវរៀបចំឲ្យមាននូវអត្ថបទទាំងស្រុងអំពី បញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតម្លៃភាពអនុលោមដែលបានធ្វើវិញ្ញត្ត (Notified) ទៅកាន់ភាគីដែលស្នើសុំក្នុងរយៈពេល១៥ថ្ងៃ នៃថ្ងៃធ្វើការក្រោយពីបានទទួលសំណើរជាលាយលក្ខអក្សរ។

៣. ភាគីនីមួយៗត្រូវទុករយៈពេល៦០ថ្ងៃយ៉ាងតិច សម្រាប់ភាគីមួយទៀតដើម្បីធ្វើការបង្ហាញយោបល់ លើកលែងតែហានិភ័យពាក់ព័ន្ធទៅនឹងសុខភាព សុវត្ថិភាព និងបរិស្ថានដែលកំពុងតែកើតឡើង ឬកំពុងតែគំរាមកំហែង ត្រូវតែលើកចេញជាវិធានការបន្ទាន់។

៤. ភាគីនីមួយៗគួរតែយកយោបល់របស់ភាគីផ្សេងទៀត ដើម្បីកំណត់យកមកធ្វើការពិចារណា និងត្រូវតែព្យាយាមផ្តល់ចម្លើយទៅយោបល់ទាំងអស់នោះតាមការស្នើសុំ។

## មាត្រា ៩
## ការពិគ្រោះយោបល់ផ្នែកបច្ចេកទេស

១. នៅពេលភាគីមួយគិតថាបញ្ញត្តិបច្ចេកទេស ឬនីតិវិធីវាយតម្លៃភាពអនុលោមពាក់ព័ន្ធរបស់ភាគីមួយទៀតបានបង្កើតការរាំងស្ទះ ដែលមានចរិកលក្ខណៈមិនចាំបាច់ចំពោះការនាំចេញរបស់ខ្លួននោះ ភាគីនោះអាចស្នើសុំកិច្ចការពិគ្រោះពិភាក្សាផ្នែកបច្ចេកទេស។ ភាគីដែលទទួលបានការស្នើសុំនោះ ត្រូវតែឆ្លើយតបទៅតាមការស្នើសុំនោះឲ្យបានមុនពេលកំណត់ដែលអាចធ្វើទៅបាន។

២. ភាគីដែលទទួលបានការស្នើសុំនោះ ត្រូវតែចូលមកក្នុងកិច្ចពិគ្រោះពិភាក្សាផ្នែកបច្ចេកទេស ក្នុងរយៈពេលមួយទៅតាមការឯកភាពគ្នា ដោយបង្ហាញអំពីការឈានទៅរកដំណោះស្រាយដោយឯកភាព

*បកប្រែក្រៅផ្លូវការ*

គ្នាដោយការពេញចិត្តរវាងភាគីទាំងសងខាង។ កិច្ចពិគ្រោះពិភាក្សាផ្នែកបច្ចេកទេសនេះ អាចប្រព្រឹត្តទៅតាមមធ្យោបាយណាមួយ ដែលបានឯកភាពគ្នាដោយភាគីពាក់ព័ន្ធ។

៣. នៅពេលគិតថានេះជាការចាំបាច់ ភាគីពាក់ព័ន្ធទាំងអស់អាចបង្កើតក្រុមការងារពិសេសមួយ (ad hoc working group) ដែលអនុម័តដោយអនុគណៈកម្មការស្តីពីស្តង់ដារបញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតម្លៃភាពអនុលោម ដើម្បីស្វែងរកដំណោះស្រាយដែលអាចសម្រេចទៅបាន និងអនុវត្តបានដែលអាចជួយសម្រួលដល់ពាណិជ្ជកម្ម។

៤. ប្រសិនបើភាគីមួយមិនទទួលយកនូវសំណើរបស់ភាគីមួយទៀត សម្រាប់ការបង្កើតក្រុមការងារពិសេសតាមការស្នើសុំរបស់ភាគីមួយទៀតនោះ ត្រូវពន្យល់ហេតុផលនៃការមិនទទួលយករបស់ខ្លួននោះ។

៥. នៅពេលមានភាពមិនអនុលោមរបស់ទំនិញនាំចូល ទៅនឹងបញ្ញត្តិបច្ចេកទេស ឬនីតិវិធីវាយតម្លៃភាពអនុលោមរបស់ភាគីទទួលទំនិញចូល ភាគីទាំងអស់ត្រូវទទួលខុសត្រូវលើគ្រប់ជំណាក់កាលដែលចាំបាច់ ដើម្បីបង្ហាញភាពមិនអនុលោមនេះ ដោយគ្មានការទុកឲ្យមានការពន្យាពេលឡើយ។

## មាត្រា ១០
## កិច្ចសហប្រតិបត្តិការផ្នែកបច្ចេកទេស

១. គ្រប់ភាគីទាំងអស់ត្រូវតែខិតខំប្រឹងប្រែងឲ្យកាន់តែខ្លាំងក្នុងការចូលរួមរបស់ពួកគេ ក្នុងផ្នែកបញ្ញត្តិបច្ចេកទេស ស្តង់ដារ និងនីតិវិធីវាយតម្លៃភាពអនុលោម ជាមួយនឹងការបង្ហាញឲ្យឃើញពីការជួយសម្រួលការចូលទៅកាន់ទីផ្សាររបស់គ្នាទៅវិញទៅមក។

២. តាមការស្នើសុំពីភាគីមួយទៀត ភាគីនីមួយៗត្រូវតែផ្តល់នូវការពិចារណាជាវិជ្ជមានទៅលើសំណើបន្ថែមក្នុងកិច្ចសហប្រតិបត្តិការដែលមានស្រាប់លើបញ្ញត្តិបច្ចេកទេស ស្តង់ដារ និងនីតិវិធីវាយតម្លៃភាពអនុលោម។ កិច្ចសហប្រតិបត្តិការនេះត្រូវផ្អែកលើការឯកភាពគ្នាអំពីពេលវេលា និងលក្ខខណ្ឌកំណត់ដែលអាចរួមមាន ប៉ុន្តែមិនកំណត់ ៖

ក. ផ្តល់ការណែនាំ ឬជំនួយការបច្ចេកទេសទាក់ទងទៅនឹងការអភិវឌ្ឍ និងការអនុវត្តស្តង់ដារ បញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតម្លៃភាពអនុលោម។

ខ. លើកទឹកចិត្តលើកិច្ចសហប្រតិបត្តិការ រវាងអង្គភាពវាយតម្លៃភាពអនុលោមរបស់ភាគីទាំងអស់

គ. ប្រើប្រាស់ការវាយតម្លៃទទួលស្គាល់ ដើម្បីវាយតម្លៃអង្គភាពវាយតម្លៃភាពអនុលោមទាំងអស់

*បកប្រែក្រៅផ្លូវការ*

ឃ. ធ្វើឲ្យប្រសើរឡើងនូវសមត្ថភាពបច្ចេកទេសក្នុងការក្រិតខ្នាត ការធ្វើតេស្ត ការធ្វើអធិការកិច្ច ការបញ្ជាក់វិញ្ញាបនបត្រ និងការវាយតម្លៃទទួលស្គាល់ ដើម្បីឆ្លើយតបទៅនឹងស្តង់ដារអន្តរជាតិដែលពាក់ព័ន្ធទាំងអស់ និងទៅនឹងអនុសាសន៍ និងការណែនាំនានា។

ង. ធ្វើកិច្ចសហប្រតិបត្តិការនៅក្នុងផ្នែកណា ដែលផ្តល់ផលប្រយោជន៍គ្នាទៅវិញទៅមក នៅលើការងារ ពាក់ព័ន្ធទៅនឹងអង្គភាពតំបន់ និងអង្គភាពអន្តរជាតិទាក់ទងទៅនឹងការអភិវឌ្ឍ និងការអនុវត្តស្តង់ដារ និងនីតិវិធីវាយតម្លៃភាពអនុលោមទាំងអស់ និង

ច. ពង្រឹងទំនាក់ទំនង និងកិច្ចសហការនៅក្នុងគណៈកម្មការ WTO/TBT និងនៅក្នុងវេទិកាអង្គការ អន្តរជាតិ ឬតំបន់ដែលពាក់ព័ន្ធដទៃទៀត។

## មាត្រា ១១
## កន្លែងទំនាក់ទំនង

១. ភាគីនីមួយៗត្រូវកំណត់ទីកន្លែងទំនាក់ទំនងមួយ ឬច្រើនសម្រាប់ភាគីនោះដែលត្រូវមានការទទួលខុសត្រូវក្នុងការសម្របសម្រួលការអនុវត្តនៅក្នុងជំពូកនេះ។

២. ភាគីនីមួយៗត្រូវផ្តល់ទៅឲ្យរាល់ភាគីផ្សេងទៀត នូវឈ្មោះទីកន្លែងទំនាក់ទំនងដែលបានកំណត់មួយ ឬច្រើនផ្សេងទៀត និងព័ត៌មានលំអិតអំពីមន្ត្រីពាក់ព័ន្ធនៅក្នុងអង្គភាពនោះរួមមាន លេខទូរស័ព្ទ ហ្វាក់ អ៊ីម៉ែល និងព័ត៌មានលំអិតមួយចំនួនទៀតដែលពាក់ព័ន្ធ។

៣. ភាគីនីមួយៗ ត្រូវធ្វើវិញ្ញត្តទៅភាគីផ្សេងទៀតឲ្យបានរហ័ស អំពីការផ្លាស់ប្តូរទីកន្លែងទំនាក់ទំនងណាមួយរបស់ខ្លួន ឬមានការកែប្រែណាមួយទៅនឹងព័ត៌មានលំអិតទាំងអស់របស់មន្ត្រីពាក់ព័ន្ធ។

## មាត្រា ១២
## ការអនុវត្ត

ចាប់ពីពេលនេះទៅភាគីទាំងអស់បង្កើតអនុគណៈកម្មការផ្នែកស្តង់ដារ បញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតំលៃភាពអនុលោម (STRACAP Sub-Committee) ដែលមានអ្នកតំណាងនៃភាគីទាំងអស់ចូលរួមដើម្បីពិនិត្យអង្កេតមើលលើការអនុវត្តនៅក្នុងជំពូកនេះ។

*បកប្រែក្រៅផ្លូវការ*

# ជំពូក ២
# វិធានការអនាម័យ និងភូតគាមអនាម័យ

## មាត្រា ១៣
## គោលបំណង

គោលបំណងនៃជំពូកនេះគឺ៖

ក. ធ្វើការសម្របសម្រួល និងជំរុញការធ្វើពាណិជ្ជកម្មទំនិញ នៅក្នុងចំណោមភាគីទាំងអស់ ដោយធានាឲ្យបានក្នុងការការពារជីវិត ឬសុខភាពមនុស្ស សត្វ ឬរុក្ខជាតិនៅក្នុងដែនដីរបស់ខ្លួន

ខ. ផ្តល់នូវតម្លាភាព និងភាពច្បាស់លាស់ដល់ភាគីនីមួយៗ ក្នុងការអនុវត្តវិធានការអនាម័យ និងភូតគាមអនាម័យ

គ. ពង្រឹងកិច្ចសហប្រតិបត្តការ រវាងអាជ្ញាធរមានសមត្ថកិច្ច នៃភាគីទាំងឡាយដែលមានការកិច្ចទទួលខុសត្រូវលើរាល់ការងារពាក់ព័ន្ធនៅក្នុងផ្នែកនេះ និង

ឃ. ធ្វើឲ្យប្រសើរឡើងនូវការអនុវត្តជាក់ស្តែង លើគោលការណ៍គ្រឹះ នៃកិច្ចព្រមព្រៀងអនាម័យ និងភូតគាមអនាម័យ។

## មាត្រា ១៤
## វិសាលភាព

ជំពូកនេះត្រូវអនុវត្តទៅលើរាល់គ្រប់វិធានការ អនាម័យនិងភូតគាមអនាម័យ ដែលអាចមានឥទ្ធិពលដោយផ្ទាល់ ឬមិនផ្ទាល់ទៅលើការធ្វើពាណិជ្ជកម្មរវាងភាគីទាំងសងខាង។

## មាត្រា ១៥
## និយមន័យ

និយមន័យប្រើសម្រាប់គោលបំណងនៃជំពូកនេះ៖

ក. និយមន័យដែលមាននៅក្នុងឧបសម្ព័ន្ធក នៃកិច្ចព្រមព្រៀង SPS ត្រូវយកមកអនុវត្ត

ខ. "អាជ្ញាធរមានសមត្ថកិច្ច" "Competent Authorities" សំដៅដល់អាជ្ញាធរទាំងឡាយនៃភាគីនីមួយៗ ដែលទទួលស្គាល់ដោយរដ្ឋាភិបាល ជាអ្នកទទួលខុសត្រូវលើការអភិវឌ្ឍនិងការគ្រប់គ្រងលើរាល់វិធានការអនាម័យ និងភូតគាមអនាម័យនៃភាគីនោះ និង

*បកប្រែក្រៅផ្លូវការ*

គ. ស្តង់ដារអន្តរជាតិ "International standard" គោលការណ៍ណែនាំ "Guideline" និងអនុសាសន៍ "Recommendations" ត្រូវតែមានន័យដូចគ្នាទៅនឹងឧបសម្ព័ន្ធក ក្នុងប្រយោគ៣ នៃកិច្ចព្រមព្រៀង SPS ។

## មាត្រា ១៦
## បទប្បញ្ញត្តិទូទៅ

១. ភាគីទាំងអស់ត្រូវបញ្ជាក់ឲ្យច្បាស់នូវសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួន ក្នុងការគោរពគ្នាទៅវិញទៅមក ក្រោមកិច្ចព្រមព្រៀងអនាម័យ និងភូតគាមអនាម័យ

២. ភាគីទាំងអស់ត្រូវប្តេជ្ញាអនុវត្តនូវគោលការណ៍គ្រឹះ នៃកិច្ចព្រមព្រៀងអនាម័យ និងភូតគាមអនាម័យ ក្នុងការអនុវត្តវិធានការអនាម័យ និងភូតគាមអនាម័យណាមួយ។

## មាត្រា ១៧
## វិភាគហានិភ័យ

ភាគីទាំងអស់ត្រូវទទួលស្គាល់ថា ការវិភាគហានិភ័យគឺជាឧបករណ៍ដ៏សំខាន់ ដើម្បីបញ្ជាក់ថា វិធានការអនាម័យ និងភូតគាមអនាម័យមានគោលគ្រឹះវិទ្យាសាស្ត្រ។ គ្រប់ភាគីទាំងអស់ត្រូវធានាថាវិធានការអនាម័យ និងភូតគាមអនាម័យដែលយកមកអនុវត្តគឺបានផ្អែកលើការវិភាគហានិភ័យពី ជីវិត ឬសុខភាពមនុស្ស សត្វ ឬរុក្ខជាតិ ស្របតាមមាត្រា៥ នៃកិច្ចព្រមព្រៀងអនាម័យ និងភូតគាមអនាម័យ ហើយត្រូវស្របទៅតាមបច្ចេកទេសដែលបានបង្កើតឡើងដោយអង្គការអន្តរជាតិពាក់ព័ន្ធ។

## មាត្រា ១៨
## សុខដុមនីយកម្ម

១. ភាគីទាំងអស់ត្រូវខំប្រឹងប្រែងក្នុងការអនុវត្ត វិធានការអនាម័យ និងភូតគាមអនាម័យរបស់ខ្លួនដោយផ្អែកលើស្តង់ដារអន្តរជាតិ សេចក្តីណែនាំ ឬអនុសាសន៍នានា។

២. ភាគីទាំងអស់ត្រូវពង្រឹងទំនាក់ទំនងសហប្រតិបត្តិការ ដោយភាពសមរម្យ និងត្រូវសម្របសម្រួលជាមួយគ្នានៅក្នុងអនុសញ្ញាអន្តរជាតិការពាររុក្ខជាតិ (IPPC), Codex Alimentarius (Codex) និងអង្គការពិភពលោកសម្រាប់សុខភាពសត្វ (OIE) ។

*បកប្រែក្រៅផ្លូវការ*

**មាត្រា ១៩**
**តំបន់ភាវូបនីយកម្ម**

ភាគីទាំងអស់ត្រូវទទួលស្គាល់នូវគោលការណ៍ នៃការធ្វើតំបន់ភាវូបនីយកម្ម និងការអនុវត្តរបស់វា ដូចដែលមានចែងនៅក្នុងមាត្រា៦ នៃកិច្ចព្រមព្រៀងអនាម័យនិងភូតគាមអនាម័យ និងស្តង់ដារ សេចក្តីណែនាំជាប់ទាក់ទងនានា ដែលបង្កើតឡើងដោយអង្គការអន្តរជាតិពាក់ព័ន្ធ។

**មាត្រា ២០**
**សមមូល**

១. ភាគីនីមួយៗត្រូវផ្តល់ការពិចារណាជាវិជ្ជមាន ចំពោះការទទួលយកវិធានការអនាម័យ និងភូតគាមអនាម័យ ដែលមានតម្លៃសមមូលរបស់ភាគីដទៃទៀត ដែលអាចសម្រេចបានកម្រិតការពារសមរម្យដូចគ្នា។

២. នៅពេលសំណើសុំ ភាគីនានាត្រូវចូលរួមធ្វើការពិគ្រោះយោបល់នានា ដែលមានគោលបំណងសម្រេចបាននូវការទទួលស្គាល់ ការរៀបចំចាត់ចែងនៃវិធានការអនាម័យ និងភូតគាមអនាម័យជាក់លាក់ដែលមានតម្លៃសមមូល។

**មាត្រា ២១**
**តម្លាភាព**

១. រាល់បណ្តាភាគីត្រូវជូនដំណឹងគ្នាទៅវិញទៅមក ដោយប្រព័ន្ធអេឡិចត្រូនិចតាមរយៈ WTO/SPS Enquiry Point រៀងៗខ្លួន នូវវិធានការអនាម័យ និងភូតគាមអនាម័យដំណាលគ្នានឹងការដាក់ជូនសេចក្តីជូនដំណឹង ទៅលេខាធិការដ្ឋានអង្គការពាណិជ្ជកម្មពិភពលោក ស្របតាមបញ្ញត្តិពាក់ព័ន្ធនៃកិច្ចព្រមព្រៀងអនាម័យ និងភូតគាមអនាម័យ។

២. ភាគីនីមួយៗត្រូវមានឯកសារពេញលេញ នៃវិធានការអនាម័យ និងភូតគាមអនាម័យដែលបានជូនដំណឹងរួច សម្រាប់ផ្តល់ឲ្យភាគីស្នើសុំក្នុងរយៈពេល ១៥ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីបានទទួលការស្នើសុំជាលាយលក្ខណ៍អក្សរ។

៣. ភាគីនីមួយៗត្រូវទុករយៈពេលយ៉ាងហោចណាស់ ៦០ថ្ងៃ ដើម្បីឲ្យភាគីផ្សេងទៀតធ្វើការបកស្រាយ លើកលែងតែករណីដែលមានហានិភ័យចំពោះជីវិត ឬសុខភាពមនុស្ស សត្វ ឬ រុក្ខជាតិ ឬមានការគំរាមកំហែងផ្នែកសុខភាព ដែលចាំបាច់ត្រូវចេញដីការឃាត់ជាបន្ទាន់។

៤. ភាគីនីមួយត្រូវផ្តល់ព័ត៌មានទាន់ពេលវេលា ពាក់ព័ន្ធនឹងបញ្ហាអនាម័យ និងភូតគាមអនាម័យដែលអាចនឹងកើតឡើងពីពាណិជ្ជកម្មទ្វេភាគីរវាងបណ្តាភាគីទាំងឡាយ។

*បកប្រែក្រៅផ្លូវការ*

## មាត្រា ២២
## សហប្រតិបត្តិការបច្ចេកទេស

១. រាល់បណ្តាភាគីយល់ព្រមស្វែងរកឱកាស ដើម្បីធ្វើកិច្ចសហប្រតិបត្តិការ និងជួយជ្រោមជ្រែងលើបញ្ហាអនាម័យ និងភូតគាមអនាម័យ ក្នុងគោលបំណងបង្កើនការយោគយល់គ្នាទៅវិញទៅមក អំពីប្រព័ន្ធច្បាប់ និងជួយសម្របសម្រួលការចូលទៅកាន់ទីផ្សាររបស់ភាគីនីមួយៗ។

២. ក្នុងករណីមានការស្នើសុំ ភាគីនីមួយៗត្រូវធ្វើការពិចារណាឲ្យបានសមស្រប ដើម្បីធ្វើសហប្រតិបត្តិការលើការងារពាក់ព័ន្ធនឹងបញ្ហាអនាម័យ និងភូតគាមអនាម័យ ដែលកិច្ចសហការនោះត្រូវស្ថិតក្នុងលក្ខខណ្ឌដែលបានឯកភាពគ្នាទៅវិញទៅមក។ វារួមបញ្ចូល ប៉ុន្តែមិនមានការដាក់កម្រិតទៅលើ៖

ក. ធ្វើការផ្លាស់ប្តូរបទពិសោធន៍ និងកិច្ចសហប្រតិបត្តិការក្នុងការអភិវឌ្ឍ និងអនុវត្តនូវវិធានការអនាម័យ និងភូតគាមអនាម័យ។

ខ. សហប្រតិបត្តិការលើការប្រតិបត្តិ ដោយផ្អែកលើគោលគំនិតតំបន់ភាវូបនីយកម្មអនុលោមទៅតាមមាត្រា៦ នៃកិច្ចព្រមព្រៀងអនាម័យនិងភូតគាមអនាម័យ និងស្តង់ដារអន្តរជាតិ គោលការណ៍ណែនាំ និងអនុសាសន៍ពាក់ព័ន្ធដើម្បីជួយសម្រួលពាណិជ្ជកម្មរវាងបណ្តាភាគី។

គ. ពង្រឹងកិច្ចសហប្រតិបត្តិការអំពី បច្ចេកទេសវិភាគក្នុងមន្ទីរពិសោធន៍ វិធីសាស្ត្រកំចាត់ជម្ងឺ /សមាសភាពចង្រៃ និងវិធីសាស្ត្រវិភាគហានិភ័យ។

ឃ. បង្កើនកិច្ចសហប្រតិបត្តិការ និងផ្លាស់ប្តូរបទពិសោធន៍រវាង WTO/SPS Enquiry Points នៃបណ្តាភាគី។

## មាត្រា ២៣
## អាជ្ញាធរមានសមត្ថកិច្ច និងចំណុចទំនាក់ទំនង

១. ភាគីនីមួយៗត្រូវចាត់តាំងមន្ត្រីទំនាក់ទំនង (Contact Point) ដើម្បីធ្វើការផ្សព្វផ្សាយនូវសំណើ ឬសេចក្តីជូនដំណឹងដោយអនុលោមទៅតាមផ្នែកនេះ។

២. ភាគីនីមួយៗត្រូវផ្តល់នូវការពិពណ៌នា អំពីអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួន និងការបែងចែកការទទួលខុសត្រូវរបស់អាជ្ញាធរមានសមត្ថកិច្ចនោះ។

*បកប្រែក្រៅផ្លូវការ*

**មាត្រា ២៤**
**ការអនុវត្ត**

ភាគីនីមួយៗត្រូវបង្កើតអនុគណៈកម្មាធិការអនាម័យ និងភូតគាមអនាម័យ ដោយមានតំណាងពីភ្នាក់ងាររដ្ឋាភិបាលពាក់ព័ន្ធនៃបណ្តាភាគី ដើម្បីត្រួតពិនិត្យនូវការប្រតិបត្តិនៅក្នុងផ្នែកនេះ។

## ជំពូក ៣
## វិធានការចុងក្រោយ

**មាត្រា ២៥**
**កិច្ចព្រមព្រៀងអន្តរជាតិដែលបានកែប្រែ ឬជំនួស**

ប្រសិនបើមានកិច្ចព្រមព្រៀងអន្តរជាតិណាមួយ ឬបទបញ្ញត្តិណាមួយនៅក្នុងនោះ យោងទៅលើពិធីសារនេះ (ឬដាក់បញ្ចូលក្នុងពិធីសារនេះ) ត្រូវបានធ្វើវិសោធនកម្ម បណ្តាភាគីត្រូវពិគ្រោះយោបល់ថាតើវាមានភាពចាំបាច់ក្នុងការធ្វើវិសោធនកម្ម លើពិធីសារនេះឬយ៉ាងណា លើកលែងតែពិធីសារនេះចែងផ្សេងពីនេះ។

**មាត្រា ២៦**
**ការធ្វើវិសោធនកម្ម**

ពិធីសារនេះអាចធ្វើវិសោធនកម្ម ដោយការព្រមព្រៀងគ្នាជាលាយល័ក្ខអក្សរដោយបណ្តាភាគី ហើយការធ្វើវិសោធនកម្មនេះ ត្រូវចូលជាធរមានតាមកាលបរិច្ឆេទនោះ ឬកាលបរិច្ឆេតដែលបានឯកភាពក្នុងចំណោមភាគីទាំងអស់។

**មាត្រា ២៧**
**ការដោះស្រាយវិវាទ**

កិច្ចព្រមព្រៀងស្តីពីយន្តការដោះស្រាយវិវាទ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌ ស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយ រវាងសមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋប្រជាមានិតចិន ត្រូវអនុវត្តលើពិធីសារនេះ។

*បកប្រែក្រៅផ្លូវការ*

**មាត្រា ២៨**

**ការតម្កល់ទុក**

សម្រាប់សមាជិកអាស៊ាន កិច្ចព្រមព្រៀងនេះ ត្រូវបានតម្កល់ទុកនៅអគ្គលេខាធិការដ្ឋានអាស៊ានដែលជាអ្នកត្រូវបញ្ជូនជាបន្ទាន់ នូវច្បាប់ចម្លងដែលបានបញ្ជាក់ត្រឹមត្រូវមួយច្បាប់ដល់សមាជិកនីមួយៗ។

**មាត្រា ២៩**

**ការចូលជាធរមាន**

១. ពិធីសារនេះចូលជាធរមាននៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៣

២. បណ្តាភាគីត្រូវបញ្ចប់នីតិវិធីក្នុងស្រុករបស់ខ្លួនសម្រាប់ការចូលជាធរមាន នៃពិធីសារនេះឱ្យបានមុនថ្ងៃទី០១ ខែមករា ឆ្នាំ២០១៣

៣. ភាគីត្រូវជូនដំណឹងពីការបញ្ចប់នីតិវិធីក្នុងស្រុករបស់ខ្លួន សម្រាប់ការចូលជាធរមាននៃពិធីសារនេះ ទៅភាគីទាំងអស់ជាលាយល័ក្ខអក្សរ។

៤. បើភាគីណាមួយមិនអាចបញ្ចប់នីតិវិធីក្នុងស្រុករបស់ខ្លួន សម្រាប់ការចូលជាធរមាននៃពិធីសារនេះ នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៣ សិទ្ធិ និងកាតព្វកិច្ចរបស់ភាគីនោះ ក្រោមពិធីសារនេះត្រូវចាប់ផ្តើមនៅកាលបរិច្ឆេទ នៃការជូនដំណឹងជាលាយលក្ខអក្សររបស់ភាគីនោះ ទៅភាគីផ្សេងទៀតទាំងអស់ថាខ្លួនបានបញ្ចប់នីតិវិធីក្នុងស្រុកសម្រាប់ការចូលជាធរមាននៃពិធីសារនេះ។

ដើម្បីជាសក្ខីភាព ហត្ថលេខីខាងក្រោម ដែលបានទទួលសិទ្ធិប្រទានពេញលេញពីរដ្ឋាភិបាលរៀងៗខ្លួន បានចុះហត្ថលេខាលើពិធីសារបួមបញ្ចូលវិធានការអនាម័យនិងភូតគាមអនាម័យ និងរបាំងបច្ចេកទេសពាណិជ្ជកម្មទៅក្នុងកិច្ចព្រមព្រៀងទំនិញ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពី សហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយ រវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋប្រជាមានិតចិន។

ធ្វើនៅភ្នំពេញ ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំពីរពាន់ដប់ពីរ ជាពីរច្បាប់ ជាភាសាអង់គ្លេស៕

| | |
|---|---|
| សម្រាប់ប្រ៊ុយណេដារូសាឡាំ | សម្រាប់រដ្ឋាភិបាលសាធារណៈរដ្ឋប្រជាមានិតចិន |
| ហត្ថលេខា | ហត្ថលេខា |
| លឹម យុកសេង | ចេង ឌីមីង |
| រដ្ឋមន្ត្រីទី២ កិច្ចការអន្តរជាតិ និងពាណិជ្ជកម្ម | រដ្ឋមន្ត្រីពាណិជ្ជកម្ម |

*បកប្រែក្រៅផ្លូវការ*

សម្រាប់ព្រះរាជាណាចក្រកម្ពុជា
ហត្ថលេខា

ចម ប្រសិទ្ធ
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីពាណិជ្ជកម្ម

សម្រាប់សាធារណរដ្ឋឥណ្ឌូនេស៊ី
ហត្ថលេខា

ហ្គីតា អឺវ៉ាវ៉ាន់ វីយ៉ាវ៉ាន់
រដ្ឋមន្ត្រីពាណិជ្ជកម្ម

សម្រាប់សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ
ហត្ថលេខា

ណាម វីយ៉ាគីត
រដ្ឋមន្ត្រី ឧស្សាហកម្ម និងពាណិជ្ជកម្ម

សម្រាប់ម៉ាឡេស៊ី
ហត្ថលេខា

ម៉ូស្តាប៉ា មហាម៉េត
រដ្ឋមន្ត្រីពាណិជ្ជកម្មអន្តរជាតិ និងឧស្សាហកម្ម

សម្រាប់សហភាពមីយ៉ាន់ម៉ា
ហត្ថលេខា

កាន ហ្ស
រដ្ឋមន្ត្រីសហភាព សម្រាប់ផែនការអន្តរជាតិ និងការអភិវឌ្ឍន៍សេដ្ឋកិច្ច

*បកប្រែក្រៅផ្លូវការ*

សម្រាប់សាធារណរដ្ឋហ្វីលីពីន
ហត្ថលេខា

 គ្រីហ្គ្គរី អេល ដូមីងហ្គ
លេខាធិការ ពាណិជ្ជកម្ម និងឧស្សាហកម្ម

សម្រាប់សាធារណរដ្ឋសិង្ហបុរី
ហត្ថលេខា

លីម អេងគាង
រដ្ឋមន្ត្រី ពាណិជ្ជកម្ម និងឧស្សាហកម្ម
សម្រាប់ព្រះរាជាណាចក្រថៃ
ហត្ថលេខា

ប៊ុនសុង ទេរីយ៉ាភីរម្យ
រដ្ឋមន្ត្រី ពាណិជ្ជកម្ម

សម្រាប់សាធារណរដ្ឋសង្គមនិយមវៀតណាម
ហត្ថលេខា

វូ ហ៊ុយ ហ្វាង
រដ្ឋមន្ត្រី ឧស្សាហកម្ម និងពាណិជ្ជកម្ម

❁❁❁❁❁

# PROTOCOL TO INCORPORATE TECHNICAL BARRIERS TO TRADE AND SANITARY AND PHYTOSANITARY MEASURES INTO THE AGREEMENT ON TRADE IN GOODS OF THE FRAMEWORK AGREEMENT ON COMPREHENSIVE ECONOMIC CO-OPERATION BETWEEN THE ASSOCIATION OF SOUTHEAST ASIAN NATIONS AND THE PEOPLE'S REPUBLIC OF CHINA

| តាំងស៊ប់ចាប់ពីថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១១ តទៅ | | | |
| ១៥៦ | លោក មោន មឿន | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ១៥៧ | លោក ហុង សុភក្រ្តគ្គន់ | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ១៥៨ | លោកស្រី មាស ភាន | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ១៥៩ | លោកស្រី សំ ស្រីទូច | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ១៦០ | លោក នុត នឿន | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ១៦១ | លោក នួង គីម | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ១៦២ | លោក ហោ គុងហាក់ | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |

| | | | |
|---|---|---|---|
| ១៦៣ | លោក ហ៊ាង ម៉ុនសាន្ត | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ១៦៤ | លោក ចាន់ សុធី | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ១៦៥ | លោក នែម ពេជ | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ១៦៦ | លោក រស់ សុធី | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ១៦៧ | លោក រ័ត្ន សារ៉ុម | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ១៦៨ | លោក មាឡូ ធុន្ថា | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ១៦៩ | លោក ផន មេឃលាង | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ១៧០ | លោក ស្រ៊ីន ចន្ទ័សុខ | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ១៧១ | លោក ខុន ខេមរា | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ១៧២ | លោក ម៉ុច សុចិន្ត | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ១៧៣ | លោក ហុក សុវណ្ណា | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ១៧៤ | លោក ជួន សុជាតិ | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ១៧៥ | លោក មាស សាម៉ួន | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ១៧៦ | លោក ម៉ៅ ស៊ីណាត | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ១៧៧ | លោក ផល កុសល | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ១៧៨ | លោក សម សុវណ្ណា | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ១៧៩ | លោក ហ៊ុន ពិសេស | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ១៨០ | លោក តេង និល | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ១៨១ | លោក ជួន ចេម | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ១៨២ | លោកស្រី ម៉ែន ចិន្ដា | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ១៨៣ | លោក ចាន់ សាមឿត | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ១៨៤ | លោក ចាន់ ម៉ុនធឿន | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ១៨៥ | លោក ធឿន គុណា | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ១៨៦ | លោក ហាឡុ សុខជា | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ១៨៧ | លោក អ៊ឹម សំអាត | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ១៨៨ | លោក លេន រុងរឿង | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ១៨៩ | លោក ស្ងួន សិរី | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ១៩០ | លោក យស់ នៃ | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |

| តាំងស៊ប់ចាប់ពីថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១២ តទៅ | | | |
|---|---|---|---|
| ១៩១ | លោក **ស៊ុត សុខា** | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ **១៤** |
| ១៩២ | លោក **ស៊ុត សារី** | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ **១៤** |

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធនិងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅ រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ២០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការផ្ទេរបញ្ចូលទៅក្នុងឋានន្តរស័ក្តិ នាយក្រមការ នៃក្របខ័ណ្ឌមន្ត្រីក្រមការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងព័ត៌មាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុងស្រុក ខណ្ឌ
- ព្រះរាជក្រឹត្យលេខ នស/រកត/០៤០០/០៥៦ ចុះថ្ងៃទី០៤ ខែ មេសា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកក្របខ័ណ្ឌមន្ត្រីក្រមការ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០០/០៧៥ ចុះថ្ងៃទី ២២ ខែ មេសា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី២០ ខែ ធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១ .-**

ត្រូវបានផ្ទេរបញ្ចូលទៅក្នុងឋានន្តរស័ក្តិ នាយក្រមការ នៃក្របខ័ណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ និងក្រសួងព័ត៌មាន នូវមន្ត្រីរាជការចំនួន **០៦រូប** ដូចមានរាយនាមខាងក្រោម :

| ល.រ | នាមត្រកូល និងនាមខ្លួន | ឋានន្តរស័ក្តិ និងថ្នាក់ចាស់ | ឋានន្តរស័ក្តិ និងថ្នាក់ថ្មី |
|---|---|---|---|
| **ក. ក្រសួងមហាផ្ទៃ** | | | |
| ១ | លោក **ខុច សារុន** | ក្រមការ ថ្នាក់លេខ ៦ | នាយក្រមការ ថ្នាក់លេខ ៦ |
| ២ | លោក **យ៉ត់ សុទេវ្យ** | ក្រមការ ថ្នាក់លេខ ៨ | នាយក្រមការ ថ្នាក់លេខ ៦ |
| ៣ | លោក **ថ្លាំ សារិន** | ក្រមការ ថ្នាក់លេខ ៨ | នាយក្រមការ ថ្នាក់លេខ ៦ |
| ៤ | លោក **ឡុង ពុន** | ក្រមការ ថ្នាក់លេខ ១០ | នាយក្រមការ ថ្នាក់លេខ ៦ |
| ៥ | លោក **ឈឿត សុន្ធរា** | ក្រមការ ថ្នាក់លេខ ១៣ | នាយក្រមការ ថ្នាក់លេខ ៦ |
| **ខ. ក្រសួងព័ត៌មាន** | | | |
| ៦ | លោកស្រី **មាស សំនាង** | ភ្នាក់ងាររដ្ឋបាល ថ្នាក់លេខ ១២ | នាយក្រមការ ថ្នាក់លេខ ៦ |

**មាត្រា ២ .-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មករា ឆ្នាំ២០១៤*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៧១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការដំឡើងឋានន្តរស័ក្តិ តែងតាំង និងសម្រួលភារកិច្ចមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពីសហលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ២០០៩ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ .-**

ត្រូវបានដំឡើងឋានន្តរស័ក្តិលោក **លី ឡេង** ពីឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ៦ ទៅជាឋានន្តរស័ក្តិ វរមន្ត្រី ថ្នាក់លេខ ៧ និងតែងតាំងជាអភិបាលរង នៃគណៈអភិបាលខេត្តកំពង់ចាម ។

**មាត្រា ២ .-**

ត្រូវបានសម្រួលភារកិច្ចលោក **ឥម សោភ័ណរតន** ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១០ ពីអភិបាលស្រុកជើងព្រៃ ឱ្យទៅបម្រើការងារនៅសាលាខេត្តកំពង់ចាម ដោយរក្សាឋានន្តរស័ក្តិ និងថ្នាក់នៅដដែល ។

**មាត្រា ៣ .-**

ត្រូវបានតែងតាំងមន្ត្រីរាជការចំនួន ០៣រូប នៅខេត្តកំពង់ចាម ដូចមានរាយនាមខាងក្រោម :

១-លោក **ឆាយ ទាំងស៊ី** ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ៧ ជាអភិបាលស្រុកជើងព្រៃ

២-លោក **ចាន់ ឥល្លី** ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ៨ ជាអភិបាលក្រុងកំពង់ចាម

៣-លោក **គេង ម៉ុនណា** ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១៣ ជាអភិបាលស្រុកត្បូងឃ្មុំ ។

**មាត្រា ៤ .-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ មាត្រា២ និងមាត្រា៣ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មករា ឆ្នាំ២០១៤

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ២២ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពីសហលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ២០០៩ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ .-**

ត្រូវបានតែងតាំងលោក **ម៉ៅ ទិសុទ្ធ** ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ៧ ជាអភិបាលស្រុកពួក នៃខេត្តសៀមរាប ។

**មាត្រា ២ .-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មករា ឆ្នាំ២០១៤*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៥៣ អនក្រ.តត

# អនុក្រឹត្យ
# ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៤៨៤ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការបង្កើតខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណូមពរការងារចាំបាច់

## សម្រេច

**មាត្រា ១.** តែងតាំងមន្ត្រីរាជការ ចំនួន ១០ រូប ជាសមាជិកក្រុមលេខាសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ ប្រធាននាយកដ្ឋាន មានដូចខាងក្រោម :

| | | | | | |
|---|---|---|---|---|---|
| ១- | លោក | សុខ សុផល | ៦- | លោក | នេត បញ្ញា |
| ២- | លោក | នង ចាន់ថុល | ៧- | លោកស្រី | សម ពេជ្របញ្ញា |
| ៣- | លោក | ហ៊ត សេងហោ | ៨- | លោកស្រី | ម៉ែន ចរិយា |
| ៤- | លោក | ឆេង វណ្ណារ៉ា | ៩- | លោកស្រី | ប៊ុន ស៊ីណា |
| ៥- | លោក | ស្មើ ឧត្តម | ១០- | លោក | មុំ វិសុទ្ធដ្ឋារ៉ូ |

**មាត្រា ២.** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីជនដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។.

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០១៤

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួលៈ
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៣.៤...អនក្រ.ត្រ.ត

# អនុក្រឹត្យ

## ស្តីពី

## ការដំឡើងឋានន្តរស័ក្តិនាយនគរបាលជាន់ខ្ពស់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១** : ត្រូវបានដំឡើងឋានន្តរស័ក្តិថ្នាក់ **វរសេនីយ៍ឯក** ជូនលោកស្រីវរសេនីយ៍ទោ **ទី សាឌី** អត្តលេខ ០៥៦៣២ នាយនគរបាលជាន់ខ្ពស់ នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា ក្រសួងមហាផ្ទៃ ។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធនិងសាមីជនដែលមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០១៤

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០៤១០ សហវ.ប្រក

# ប្រកាស
## ស្តីពី
## ការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋាននិងអង្គភាព ក្រោមឱវាទរបស់អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស /រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

# ស ម្រេ ច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ១**.-

ប្រកាសនេះ មានគោលដៅកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋាន និង អង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធនៃក្រសួង សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**ប្រការ២**.-

ប្រកាសនេះមានគោលបំណងដូចខាងក្រោម៖

- រៀបចំបេសកកម្មនិងរចនាសម្ព័ន្ធរបស់នាយកដ្ឋាននិងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ
- រៀបចំតួនាទីនិងភារកិច្ចរបស់នាយកដ្ឋាននិងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ
- ធានាគុណភាព និងប្រសិទ្ធភាពនៃលទ្ធផលបំពេញការងារ ក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ ។

**ប្រការ៣**.-

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះគ្រប់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ។

## ជំពូកទី២
## បេសកកម្មនិងរចនាសម្ព័ន្ធ

**ប្រការ៤**.-

អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ បំពេញមុខងារជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើបេសកកម្មគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ។

**ប្រការ៥**.-

អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ មានភារកិច្ច ដូចតទៅ÷

- រៀបចំសេចក្តីព្រាងច្បាប់ គោលនយោបាយ យុទ្ធសាស្ត្រ និងលិខិតបទដ្ឋាននានាទាក់ទង នឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ
- គ្រប់គ្រង និងជំរុញការធ្វើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរបស់រដ្ឋ នៅទូទាំងប្រទេស
- ស្រាវជ្រាវ និងគ្រប់គ្រងទ្រព្យឥតម្ចាស់ និងមរតកឥតបណ្តឹង
- គ្រប់គ្រងការប្រមូលចំណូលមិនមែនសារពើពន្ធ
- គ្រប់គ្រងភាគហ៊ុនរបស់រដ្ឋ និងដើមទុនរបស់រដ្ឋ
- គ្រប់គ្រងសហគ្រាសសាធារណៈ អង្គភាពសាធារណៈ និងអង្គភាពរដ្ឋដទៃទៀត
- ប្រមូលផ្តុំព័ត៌មានពាក់ព័ន្ធនឹងការងារឯកជនភាវូបនីយកម្ម ការជំរះបញ្ជីសហគ្រាសសាធារណៈ និងអង្គភាពរដ្ឋដទៃទៀត
- គ្រប់គ្រង និងរៀបចំបញ្ជីសម្បទានដីសេដ្ឋកិច្ច សម្បទានព្រៃឈើ សម្បទានរ៉ែ និងសម្បទានដទៃទៀត ដែលបានផ្តល់ឱ្យវិស័យឯកជន
- រៀបចំនីតិវិធី វាយតំលៃការដាក់ជួល លក់ ដូរ ផ្ទេរសិទ្ធិទ្រព្យសម្បត្តិរដ្ឋ
- ស្រាវជ្រាវរកប្រភពចំណូលមិនមែនសារពើពន្ធផ្សេងៗទៀត
- ចូលរួមរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុ ។

**ប្រការ៦**.-

អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ មាននាយកដ្ឋានក្រោមឱវាទចំនួន ៤ និងលេខាធិការដ្ឋាន១ ដូចខាងក្រោម÷

- នាយកដ្ឋានសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ
- នាយកដ្ឋានចំណូលពីទ្រព្យសម្បត្តិរដ្ឋ
- នាយកដ្ឋានចំណូលសាធារណៈ
- នាយកដ្ឋានសហគ្រាសសាធារណៈ
- លេខាធិការដ្ឋាន

នាយកដ្ឋាននីមួយៗមានការិយាល័យចំណុះមួយចំនួន តាមការចាំបាច់។

អង្គការលេខនៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធត្រូវបាន កំណត់នៅក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ ។

**ប្រការ៧.-**

- នាយកដ្ឋាននីមួយៗនៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការ
- លេខាធិការដ្ឋាននៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ ដឹកនាំដោយប្រធានមួយរូប មានឋានៈស្មើអនុប្រធាននាយកដ្ឋាន និងអមដោយអនុប្រធានមួយចំនួនជាជំនួយការ មានឋានៈស្មើប្រធានការិយាល័យ
- ការិយាល័យចំណុះនាយកដ្ឋាននីមួយៗ នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួនជាជំនួយការ ។

## ជំពូកទី៣
## នាយកដ្ឋានសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ

**ប្រការ៨.-**

តួនាទី និងភារកិច្ចរបស់នាយកដ្ឋានសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ មានដូចខាងក្រោម ÷

- បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ លើការងារគ្រប់គ្រងបញ្ជីសារពើភ័ណ្ឌ
- រៀបចំសេចក្តីព្រាងច្បាប់ គោលនយោបាយ យុទ្ធសាស្ត្រ និងលិខិតបទដ្ឋាននានា ទាក់ទងនឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងផ្សព្វផ្សាយនីតិវិធីថ្មីៗ ដែលដាក់ចេញក្នុងការជំរុញ ការកែលំអ និងការកែសម្រួលនៃការរៀបចំ និងគ្រប់គ្រងបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ
- គ្រប់គ្រង និងជំរះបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ព្រមទាំងតម្កល់កិច្ចសន្យា កិច្ចព្រមព្រៀង សៀវភៅបន្ទុក ពីការជួល វិនិយោគ សម្បទាន និងការធ្វើឯកជនភាវូបនីយកម្មទ្រព្យសម្បត្តិរបស់រដ្ឋ

- គ្រប់គ្រងការងារប្រទានកម្មទ្រព្យសម្បត្តិរបស់រដ្ឋ
- ចូលរួមរៀបចំគម្រោងថវិកាប្រចាំឆ្នាំ ក្នុងដំណើរការរៀបចំសេចក្តីព្រាងច្បាប់ ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងនៃឆ្នាំនីមួយៗ។

**ប្រការ៩.-**

នាយកដ្ឋានសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ មានការិយាល័យក្រោមឱវាទចំនួនបី ដូចខាងក្រោម៖

- ការិយាល័យសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋថ្នាក់ជាតិ
- ការិយាល័យសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋថ្នាក់ក្រោមជាតិ
- ការិយាល័យសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋថ្នាក់នីតិបុគ្គលសាធារណៈ ។

**ប្រការ១០.-**

តួនាទី និងភារកិច្ចរបស់ការិយាល័យសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋថ្នាក់ជាតិ មានដូចខាងក្រោម ៖

- ចូលរួមផ្តួចផ្តើម និងរៀបចំលិខិតបទដ្ឋានគតិយុត្ត សម្រាប់ការគ្រប់គ្រងសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋថ្នាក់ជាតិ
- គ្រប់គ្រង តម្កល់ និងជំរះបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ដែលកាន់កាប់ដោយក្រសួង ស្ថាប័ន និងអង្គភាពក្រោមឱវាទក្រសួង ស្ថាប័នទាំងនោះ
- ផ្តួចផ្តើម រៀបចំ និងកែលំអប្រព័ន្ធទិន្នន័យមូលដ្ឋាន សំរាប់គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋទាំងអស់នៅទូទាំងប្រទេស រួមទាំងបញ្ជីជួល លក់ ដូរទ្រព្យសម្បត្តិរដ្ឋ បញ្ជីសម្បទានដីសេដ្ឋកិច្ច បញ្ជីសម្បទានព្រៃឈើ បញ្ជីសម្បទានរ៉ែ និងសម្បទានទ្រព្យសម្បត្តិរដ្ឋដទៃទៀត
- គ្រប់គ្រងការងារផ្ទេរ និងប្រទានកម្មទ្រព្យសម្បត្តិរដ្ឋថ្នាក់ជាតិ
- ចូលរួមពិធីប្រគល់ទទួលទ្រព្យសម្បត្តិរដ្ឋ ដែលកាន់កាប់ដោយក្រសួង ស្ថាប័ន និងអង្គភាពក្រោមឱវាទក្រសួង ស្ថាប័នទាំងនោះ
- ផ្សព្វផ្សាយនីតិវិធីថ្មីៗ ពិនិត្យតាមដាន និងផ្ទៀងផ្ទាត់ជាប្រចាំ ដើម្បីធ្វើបច្ចុប្បន្នភាពបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ដែលកាន់កាប់ដោយក្រសួង ស្ថាប័ន និងអង្គភាពក្រោមឱវាទក្រសួង ស្ថាប័នទាំងនោះ

- ផ្សព្វផ្សាយនីតិវិធីថ្មីៗ ដែលដាក់ចេញក្នុងការជំរុញ ការកែលំអ និងការ កែសម្រួលការរៀបចំ និងគ្រប់គ្រងបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ
- កសាងផែនការចំណូល និងបំណុលប្រចាំឆ្នាំពីការជំរះបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋទាំងអស់
- ធ្វើរបាយការណ៍ទៀងទាត់ស្តីពីសកម្មភាពការងាររបស់ការិយាល័យសាមី ។

**ប្រការ១១ .-**

តួនាទី និងភារកិច្ចរបស់ការិយាល័យសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋថ្នាក់ក្រោមជាតិមានដូចខាងក្រោម ÷

- ចូលរួមផ្តួចផ្តើម និងរៀបចំលិខិតបទដ្ឋានគតិយុត្ត សម្រាប់ការគ្រប់គ្រងសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋថ្នាក់ក្រោមជាតិ
- គ្រប់គ្រង តម្កល់ និងជំរះបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ របស់មន្ទីរ ឬ អង្គភាព នៃក្រសួង ស្ថាប័ន នៅថ្នាក់រាជធានី ខេត្ត
- គ្រប់គ្រងការងារផ្ទេរ និងប្រទានកម្មទ្រព្យសម្បត្តិរដ្ឋ របស់មន្ទីរ ឬ អង្គភាព នៃក្រសួង ស្ថាប័ន នៅថ្នាក់រាជធានី ខេត្ត
- ចូលរួមពិធីប្រគល់ទទួលទ្រព្យសម្បត្តិរដ្ឋ ដែលកាន់កាប់ដោយមន្ទីរ ឬ អង្គភាពនៃក្រសួងស្ថាប័ន នៅថ្នាក់រាជធានី ខេត្ត
- ពិនិត្យតាមដាន និងផ្ទៀងផ្ទាត់ជាប្រចាំ នូវបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋដែលកាន់កាប់ដោយមន្ទីរ ឬអង្គភាព នៃក្រសួងស្ថាប័ន នៅថ្នាក់ខេត្ត រាជធានី
- ធ្វើរបាយការណ៍ទៀងទាត់ស្តីពីសកម្មភាពការងាររបស់ការិយាល័យសាមី ។

**ប្រការ១២ .-**

តួនាទី និងភារកិច្ចរបស់ការិយាល័យសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋថ្នាក់នីតិបុគ្គលសាធារណៈមានដូចខាងក្រោម ÷

- ចូលរួមផ្តួចផ្តើម និងរៀបចំលិខិតបទដ្ឋានគតិយុត្ត សម្រាប់ការគ្រប់គ្រងសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋថ្នាក់នីតិបុគ្គលសាធារណៈ
- គ្រប់គ្រង តម្កល់ និងជំរះបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់សហគ្រាសសាធារណៈ

គ្រឹះស្ថានសាធារណៈរដ្ឋបាល និងនីតិបុគ្គលសាធារណៈដទៃទៀត

- គ្រប់គ្រងការងារផ្ទេរ និងប្រទានកម្មទ្រព្យសម្បត្តិរដ្ឋ របស់សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងនីតិបុគ្គលសាធារណៈដទៃទៀត
- ពិនិត្យតាមដាន និងផ្ទៀងផ្ទាត់ជាប្រចាំនូវបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពនីតិបុគ្គលសាធារណៈដទៃទៀត
- ចូលរួមពិធីប្រគល់ទទួលទ្រព្យសម្បត្តិរដ្ឋរបស់សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពនីតិបុគ្គលសាធារណៈដទៃទៀត
- ធ្វើរបាយការណ៍ទៀងទាត់ស្តីពីសកម្មភាពការងាររបស់ការិយាល័យសាមី ។

## ជំពូកទី៤
## នាយកដ្ឋានចំណូលពីទ្រព្យសម្បត្តិរដ្ឋ

**ប្រការ១៣**.-

តួនាទី និងភារកិច្ចរបស់នាយកដ្ឋានចំណូលពីទ្រព្យសម្បត្តិរដ្ឋ នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ មានដូចខាងក្រោម÷

- បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ លើការងារគ្រប់គ្រងចំណូលពីទ្រព្យសម្បត្តិរដ្ឋ ដោយផ្អែកលើមូលដ្ឋានច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធ
- ផ្តួចផ្តើម និងចូលរួមរៀបចំសេចក្តីព្រាងច្បាប់ គោលនយោបាយ យុទ្ធសាស្ត្រ និងលិខិតបទដ្ឋាននានា ទាក់ទងនឹងការគ្រប់គ្រងចំណូលពីទ្រព្យសម្បត្តិរដ្ឋ
- គ្រប់គ្រងការងារឯកជនភាវូបនីយកម្មទ្រព្យសម្បត្តិរបស់រដ្ឋ ផ្អែកតាមការសម្រេចរបស់រាជរដ្ឋាភិបាល
- គ្រប់គ្រងចំណូល និងតាមដានការអនុវត្តកិច្ចសន្យា សៀវភៅបន្ទុក ពីការជួលវិនិយោគ សម្បទាន និងការធ្វើឯកជនភាវូបនីយកម្មទ្រព្យសម្បត្តិរបស់រដ្ឋ
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ស្តីពីស្ថានភាពនៃការអនុវត្តចំណូល និងស្ថានភាពបំណុល
- ចូលរួមរៀបចំគម្រោងថវិកាប្រចាំឆ្នាំ ក្នុងដំណើរការរៀបចំសេចក្តីព្រាងច្បាប់ ស្តីពី

ហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងនៃឆ្នាំនីមួយៗ។

**ប្រការ១៤** .-

នាយកដ្ឋានចំណូលពីទ្រព្យសម្បត្តិរដ្ឋ មានការិយាល័យក្រោមឱវាទចំនួនបី ដូចខាងក្រោម÷

- ការិយាល័យចំណូលទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ
- ការិយាល័យចំណូលសម្បទានទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ
- ការិយាល័យចំណូលធនធានធម្មជាតិ ។

**ប្រការ១៥** .-

តួនាទី និងភារកិច្ចរបស់ការិយាល័យចំណូលទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ មានដូចខាងក្រោម ÷

- ចូលរួមផ្តួចផ្តើម និងរៀបចំលិខិតបទដ្ឋានគតិយុត្ត សម្រាប់ការគ្រប់គ្រងចំណូលទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ
- កសាងផែនការចំណូល និងបំណុលប្រចាំឆ្នាំពីការលក់ ជួល សហគ្រាស រោងចក្រ ចលនៈ- អចលនៈវត្ថុ និងប្រាក់លំអៀងពីការដូរទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ
- គ្រប់គ្រង និងពិនិត្យការងារនៃការលក់ ជួល ដូរ ផ្ទេរ ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ
- ពិនិត្យ កែសំរួលកិច្ចសន្យា និងតាមដានការអនុវត្តកិច្ចសន្យាលក់ ជួល ដូរ ចលនៈ អចលនៈវត្ថុ ដែលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ
- តាមដាន និងជំរុញការប្រមូលចំណូលនិងបំណុលពីការលក់ ដូរ និង ជួលសហគ្រាស រោងចក្រ និងចលនៈ-អចលនៈវត្ថុ ដែលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ស្ថិតនៅក្រោមការកាន់កាប់របស់ក្រសួង ស្ថាប័ន និងរាជធានី ខេត្ត
- រៀបចំគម្រោងចំណូលទ្រព្យសម្បត្តិរបស់រដ្ឋ ដែលជាគម្រោងថវិកាប្រចាំឆ្នាំ ដើម្បីបញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំនីមួយៗ
- ធ្វើរបាយការណ៍សរុបស្តីពីសកម្មភាពការងាររបស់នាយកដ្ឋានសាមី ។

**ប្រការ១៦**.-

តួនាទី និងភារកិច្ចរបស់ការិយាល័យចំណូលសម្បទានទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មានដូចខាងក្រោម ÷

- ចូលរួមផ្តួចផ្តើម និងរៀបចំលិខិតបទដ្ឋានគតិយុត្ត សម្រាប់ការគ្រប់គ្រងចំណូលទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ
- ស្រាវជ្រាវរកប្រភពចំណូលថ្មីៗនៃចំណូល សម្បទានទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ រួមមាន ជលផល ភាស៊ីផ្សារ កំពង់ចម្លង ចំណត សត្តឃាតដ្ឋាន អនាម័យសត្វ សេវាប្រមូលសំរាម និងចំណូលពីសម្បទានទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋដទៃទៀត
- រៀបចំនីតិវិធីសំរាប់ប្រមូលចំណូលពីសម្បទានទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ
- តាមដានការអនុវត្តកិច្ចសន្យា ឬ សៀវភៅបន្ទុកនានា ដែលទាក់ទងនឹងប្រភេទចំណូលពីសម្បទានទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ
- ចូលរួមសំរបសំរួល និងដោះស្រាយបញ្ហាដែលកើតឡើងជុំវិញការអនុវត្តកិច្ចសន្យាចំណូលពីសម្បទានទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ
- គ្រប់គ្រងកិច្ចសន្យា និងបញ្ជីសារពើភ័ណ្ឌនៃទីតាំងផ្សារ កំពង់ចម្លង សត្តឃាតដ្ឋាន ទីតាំងដាក់សំរាមដែលជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ
- រៀបចំគម្រោងចំណូលពីសម្បទានទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ដែលជាគម្រោងថវិកាប្រចាំឆ្នាំ ដើម្បីបញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំនីមួយៗ
- ធ្វើរបាយការណ៍ទៀងទាត់ស្តីពីសកម្មភាពការងាររបស់ការិយាល័យសាមី ។

**ប្រការ១៧**.-

តួនាទី និងភារកិច្ចរបស់ការិយាល័យចំណូលធនធានធម្មជាតិ មានដូចខាងក្រោម ÷

- ចូលរួមផ្តួចផ្តើម និងរៀបចំលិខិតបទដ្ឋានគតិយុត្ត សម្រាប់ការគ្រប់គ្រងចំណូលធនធានធម្មជាតិ
- គ្រប់គ្រង និងជំរុញការរៀបចំបញ្ជីសារពើភ័ណ្ឌសម្បទានដីសេដ្ឋកិច្ច ព្រៃឈើ រ៉ែ នៅទូទាំងប្រទេស

- គ្រប់គ្រងចំណូលប្រចាំឆ្នាំពីធនធានធម្មជាតិ សម្បទាន ដីសេដ្ឋកិច្ច និងគម្រោងសម្បទានដទៃទៀត
- តាមដាន និងជំរុញការប្រមូលចំណូល ប្រាក់កក់ និងបំណុល ពីព្រៃឈើ រ៉ែ សម្បទានដីសេដ្ឋកិច្ច និងពីធនធានធម្មជាតិដទៃទៀត
- ពិនិត្យ កែសំរួល និងតាមដានការអនុវត្តកិច្ចសន្យានានា ពាក់ព័ន្ធនឹងសម្បទានដីសេដ្ឋកិច្ច ព្រៃឈើ រ៉ែ សម្បទានដីសេដ្ឋកិច្ច និងពីធនធានធម្មជាតិ ដទៃទៀត
- រៀបចំ និងពិនិត្យផ្តល់យោបល់លើឯកសារស្នើសុំពាក់ព័ន្ធនឹងសម្បទានដីសេដ្ឋកិច្ច ព្រៃឈើ រ៉ែ និងពីធនធានធម្មជាតិដទៃទៀត
- រៀបចំគម្រោងចំណូលពីសម្បទានដីសេដ្ឋកិច្ច ព្រៃឈើ រ៉ែ សម្បទានដីសេដ្ឋកិច្ច និងពីធនធានធម្មជាតិដទៃទៀត ដែលជាគម្រោងថវិកាប្រចាំឆ្នាំ ដើម្បីបញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់ ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំនីមួយៗ
- ធ្វើរបាយការណ៍ទៀងទាត់ស្តីពីសកម្មភាពការងាររបស់ការិយាល័យសាមី ។

## ជំពូកទី៥
## នាយកដ្ឋានចំណូលសាធារណៈ

**ប្រការ១៨**.-

តួនាទី និងភារកិច្ចរបស់នាយកដ្ឋានចំណូលសាធារណៈ នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ មានដូចខាងក្រោម ÷

- បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ លើការងារគ្រប់គ្រងចំណូលសាធារណៈ
- ផ្តួចផ្តើម និងចូលរួមរៀបចំសេចក្តីព្រាងច្បាប់ គោលនយោបាយ យុទ្ធសាស្ត្រ និងលិខិតបទដ្ឋាននានា ទាក់ទងនឹងការគ្រប់គ្រងចំណូលសាធារណៈរបស់រដ្ឋ និងចំណូលបែងចែកតាមកិច្ចសន្យា និងកិច្ចព្រមព្រៀងរបស់ក្រសួង ស្ថាប័នជាមួយផ្នែកឯកជន
- សិក្សារកប្រភពចំណូលសាធារណៈដទៃទៀត ព្រមទាំងគ្រប់គ្រងការងារផ្តល់រង្វាន់លើកទឹកចិត្ត លើការងារខិតខំប្រមូលចំណូលមិនមែនសារពើពន្ធ
- ចូលរួមដោះស្រាយទំនាស់វិវាទ លើការអនុវត្តចំណូលមិនមែនសារពើពន្ធ តាមផ្លូវ

ច្បាប់ និងតុលាការ

- គ្រប់គ្រងចំណូល និងបូកសរុបប្រចាំខែ ស្តីពីស្ថានភាពអនុវត្តចំណូល និងបំណុល ពីចំណូលសាធារណៈ ដែលបែងចែកតាមរយៈកិច្ចសន្យានិងកិច្ចព្រមព្រៀង ផ្អែកតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- ចូលរួមរៀបចំគម្រោងថវិកាប្រចាំឆ្នាំ ក្នុងដំណើរការរៀបចំសេចក្តីព្រាងច្បាប់ ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងនៃឆ្នាំនីមួយៗ។

**ប្រការ១៩**.-

នាយកដ្ឋានចំណូលសាធារណៈ មានការិយាល័យក្រោមឱវាទចំនួនបួន ដូចខាងក្រោម៖

- ការិយាល័យចំណូលសាធារណៈវិស័យរដ្ឋបាលទូទៅ
- ការិយាល័យចំណូលសាធារណៈវិស័យការពារជាតិនិងសន្តិសុខ
- ការិយាល័យចំណូលសាធារណៈវិស័យសង្គមកិច្ច
- ការិយាល័យចំណូលសាធារណៈវិស័យសេដ្ឋកិច្ច ។

**ប្រការ២០**.-

តួនាទី និងភារកិច្ចរបស់ការិយាល័យចំណូលសាធារណៈវិស័យរដ្ឋបាលទូទៅ, ការិយាល័យចំណូលសាធារណៈវិស័យការពារជាតិនិងសន្តិសុខ, ការិយាល័យចំណូលសាធារណៈវិស័យសង្គមកិច្ច, និងការិយាល័យចំណូលសាធារណៈវិស័យសេដ្ឋកិច្ច មានដូចខាងក្រោម ÷

- ចូលរួមផ្តួចផ្តើម រៀបចំ និងកែសម្រួលលិខិតបទដ្ឋាននានា ដែលពាក់ព័ន្ធនឹងការផ្តល់សេវាសាធារណៈ និងការផ្តល់រង្វាន់លើកទឹកចិត្តរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងចូលរួមដោះស្រាយទំនាស់វិវាទនៃការប្រមូលចំណូលមិនមែនសារពើពន្ធ
- សិក្សាស្វែងយល់ស៊ីជម្រៅ អំពីប្រភពចំណូល និងនីតិវិធី បែបបទនៃការប្រមូលចំណូលនៅតាមក្រសួង ស្ថាប័ន មន្ទីរជំនាញ និងអង្គភាពរបស់រដ្ឋ
- ពិនិត្យឡើងវិញលើប្រភពចំណូលមួយចំនួន ដែលមានសក្តានុពល រួមទាំងចំណូលបែងចែកតាមកិច្ចសន្យា និងកិច្ចព្រមព្រៀង
- សិក្សាស្រាវជ្រាវរកប្រភពចំណូលសាធារណៈដទៃទៀត

- ប្រមូលផ្តុំស្ថិតិទិន្នន័យលម្អិតតាមប្រភេទសេវាសាធារណៈនីមួយៗ ដែលពាក់ព័ន្ធនឹងការប្រមូលចំណូលរបស់ក្រសួង ស្ថាប័ន មន្ទីរជំនាញ និងអង្គភាពរបស់រដ្ឋ
- តាមដាន និងពិនិត្យផ្ទៀងផ្ទាត់ការអនុវត្តចំណូលពីការផ្តល់សេវាសាធារណៈ និងការផ្តល់រង្វាន់លើកទឹកចិត្តនៅតាមក្រសួង ស្ថាប័ន មន្ទីរ ជំនាញ និងអង្គភាពរបស់រដ្ឋ
- សហការជាមួយក្រសួងស្ថាប័ន អនុវត្តការតឹងទារបំណុល និងលើកវិធានការតឹងទារ ឬជម្រះបំណុល
- រៀបចំលិខិតពិនិត្យបញ្ជាក់លើសលាកបំត្រចំណូលថវិកាជាតិ សម្រាប់ការអនុវត្តនីតិវិធីទូទាត់ប្រាក់រង្វាន់លើកទឹកចិត្តរបស់ក្រសួងស្ថាប័នរដ្ឋបាលកណ្តាល និងធ្វើកំណត់បង្ហាញដាក់ជូនអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ ដើម្បីពិនិត្យ និងសម្រេច
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ស្តីពីស្ថានភាពនៃការអនុវត្តចំណូល និងស្ថានភាពបំណុលរបស់ក្រសួង ស្ថាប័ន មន្ទីរជំនាញ និងអង្គភាព នៃរដ្ឋបាលថ្នាក់ជាតិ
- ចូលរួមរៀបចំគម្រោងថវិកាប្រចាំឆ្នាំ ក្នុងដំណើរការរៀបចំសេចក្តីព្រាងច្បាប់ ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងនៃឆ្នាំនីមួយៗ
- ធ្វើរបាយការណ៍ទៀងទាត់ស្តីពីសកម្មភាពការងាររបស់ការិយាល័យសាមី។

**ប្រការ២១.-**

ការិយាល័យចំណូលសាធារណៈវិស័យរដ្ឋបាលទូទៅទទួលបន្ទុកបំពេញភារកិច្ចលើការងារគ្រប់គ្រងចំណូលរបស់ក្រសួងព្រះបរមរាជវាំង, រដ្ឋសភា, ព្រឹទ្ធសភា, ក្រុមប្រឹក្សាធម្មនុញ្ញ, ទីស្តីការគណៈរដ្ឋមន្ត្រី, ក្រសួងមុខងារសាធារណៈ, ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច, ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ក្រសួងផែនការ, ក្រសួងយុត្តិធម៌, អាជ្ញាធរសវនកម្មជាតិ, និងស្ថាប័នប្រឆាំងអំពើពុករលួយ។

ការិយាល័យចំណូលសាធារណៈវិស័យរដ្ឋបាលទូទៅ ទទួលបន្ទុកធ្វើរបាយការណ៍សរុបស្តីពីសកម្មភាពការងាររបស់នាយកដ្ឋានសាមី ។

**ប្រការ២២.-**

ការិយាល័យចំណូលសាធារណៈវិស័យការពារជាតិនិងសន្តិសុខទទួលបន្ទុកបំពេញភារកិច្ចលើការងារគ្រប់គ្រងចំណូលរបស់ក្រសួងការពារជាតិ និងក្រសួងមហាផ្ទៃ ។

បន្ថែមលើភារកិច្ចដែលបានកំណត់នៅក្នុងប្រការ២០នៃប្រកាសនេះ ការិយាល័យចំណូលសាធារណៈវិស័យការពារជាតិ និងសន្តិសុខមានភារកិច្ចគ្រប់គ្រងសន្និធិនិងបើកផ្តល់បង្កាន់ដៃបង់ប្រាក់ សម្រាប់ការប្រមូលចំណូលមិនមែនសារពើពន្ធ ព្រមទាំងធ្វើរបាយការណ៍អំពីស្ថានភាពបើកផ្តល់បង្កាន់ដៃបង់ប្រាក់ប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំ។ លើកគម្រោងបោះពុម្ពបង្កាន់ដៃបង់ប្រាក់ប្រចាំឆ្នាំ សម្រាប់ការប្រើប្រាស់ប្រមូលចំណូលមិនមែនសារពើពន្ធរបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ។

**ប្រការ២៣.-**

ការិយាល័យចំណូលសាធារណៈវិស័យសង្គមកិច្ចទទួលបន្ទុកបំពេញភារកិច្ចលើការងារគ្រប់គ្រងចំណូលរបស់ក្រសួងព័ត៌មាន, ក្រសួងសុខាភិបាល, ក្រសួងអប់រំ យុវជន និង កីឡា, ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ, ក្រសួងបរិស្ថាន, ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, ក្រសួងធម្មការ និងសាសនា, ក្រសួងកិច្ចការនារី, និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**ប្រការ២៤.-**

ការិយាល័យចំណូលសាធារណៈវិស័យសេដ្ឋកិច្ចទទួលបន្ទុកបំពេញភារកិច្ចលើការងារគ្រប់គ្រងចំណូលរបស់រដ្ឋលេខាធិការដ្ឋាន អាកាសចរណ៍ស៊ីវិល, ក្រសួងឧស្សាហកម្ម និងសិប្បកម្ម, ក្រសួងរ៉ែ និងថាមពល, ក្រសួងពាណិជ្ជកម្ម, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងអភិវឌ្ឍន៍ជនបទ, ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍, ក្រសួងសាធារណការ និងដឹកជញ្ជូន, ក្រសួងទេសចរណ៍, ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, និងក្រសួងធនធានទឹក និងឧតុនិយម។

## ជំពូកទី៦

## នាយកដ្ឋានសហគ្រាសសាធារណៈ

**ប្រការ២៥.-**

តួនាទីនិងភារកិច្ចរបស់នាយកដ្ឋានសហគ្រាសសាធារណៈ នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ មានដូចខាងក្រោម ÷

- បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ លើការងារគ្រប់គ្រងសហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពនីតិបុគ្គលសាធារណៈដទៃទៀត
- ផ្តួចផ្តើម និងចូលរួមរៀបចំសេចក្តីព្រាងច្បាប់ គោលនយោបាយ យុទ្ធសាស្ត្រ និងលិខិតបទដ្ឋាននានា ទាក់ទងនឹងការគ្រប់គ្រងសហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពនីតិបុគ្គលសាធារណៈដទៃទៀត
- ជំរុញ និងជួយរៀបចំអង្គភាពរដ្ឋ រួមទាំងក្រុមហ៊ុនចំរុះរដ្ឋទាំងឡាយដែលជាគោលដៅនៃការកែទំរង់សហគ្រាសរដ្ឋ ដើម្បីឱ្យអនុវត្តរបបសហគ្រាសសាធារណៈ ឬ ជំរះបញ្ជី
- ជួយរៀបចំឯកសារគតិយុត្ត សម្រាប់បង្កើតសហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពនីតិបុគ្គលសាធារណៈដទៃទៀត
- ពិនិត្យផែនការប្រចាំឆ្នាំ ចុះពិនិត្យការអនុវត្តប្រចាំឆ្នាំ និងពិនិត្យការបិទបញ្ជីគណនេយ្យប្រចាំឆ្នាំ ព្រមទាំងជំរុញការបង់ចំណូលចូលថវិកាជាតិ របស់សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពនីតិបុគ្គលសាធារណៈដទៃទៀត
- តាមដាន និងពិនិត្យស្ថានភាពហិរញ្ញវត្ថុរបស់សហគ្រាសសាធារណៈ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពនីតិបុគ្គលសាធារណៈដទៃទៀត
- ចូលរួមរៀបចំគម្រោងថវិកាប្រចាំឆ្នាំ ក្នុងដំណើរការរៀបចំសេចក្តីព្រាងច្បាប់ ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងនៃឆ្នាំនីមួយៗ។

**ប្រការ២៦**.-

នាយកដ្ឋានសហគ្រាសសាធារណៈ មានការិយាល័យក្រោមឱវាទចំនួនបី ដូចខាងក្រោម៖
- ការិយាល័យសហគ្រាសសាធារណៈ
- ការិយាល័យគ្រឹះស្ថានសាធារណៈរដ្ឋបាល
- ការិយាល័យអង្គភាពនីតិបុគ្គលសាធារណៈ ។

**ប្រការ២៧**.-

តួនាទីនិងភារកិច្ចរបស់ការិយាល័យសហគ្រាសសាធារណៈ មានដូចខាងក្រោម៖
- ចូលរួមផ្តួចផ្តើម និងរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ និងលិខិតបទដ្ឋានគតិយុត្តសម្រាប់ការកែទម្រង់សហគ្រាសសាធារណៈ ស្របតាមការរីកចម្រើននៃសេដ្ឋកិច្ចជាតិ
- ជំរុញ និងរៀបចំអង្គភាពរដ្ឋដែលជាគោលដៅនៃការកែទម្រង់ទៅជាសហគ្រាសសាធារណៈ
- ចូលរួមកំណត់ដើមទុនដំបូង ឬការជម្រះបញ្ជីសម្រាប់ការបង្កើត ការរំលាយបញ្ចូល

ការបំបែក ឬការកែលម្អនៃសហគ្រាសសាធារណៈ
- ពិនិត្យការបិទបញ្ជីគណនេយ្យប្រចាំឆ្នាំ ព្រមទាំងតាមដានស្ថានភាពប្រែប្រួល នៃបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ របស់សហគ្រាសសាធារណៈនីមួយៗ
- ពិនិត្យ វាយតម្លៃ និងធ្វើការជម្រះបញ្ជីចលនទ្រព្យ និងអចលនទ្រព្យរបស់សហគ្រាសសាធារណៈ ដែលផុតអាយុកាលប្រើប្រាស់ ឬ ខូចខាត
- តាមដាន និងពិនិត្យជាប្រចាំ អំពីស្ថានភាពហិរញ្ញវត្ថុរបស់សហគ្រាសសាធារណៈ
- សម្របសម្រួលជាមួយសហគ្រាសសាធារណៈទាំងអស់ ក្នុងការរៀបចំគម្រោងចំណូលពីសហគ្រាសសាធារណៈ ដែលជាចំណូលទទួលបានពីប្រាក់ចំណេញ (ភាគលាភ) ដើម្បីបញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំនីមួយៗ
- ពិនិត្យ និងលើកយោបល់ជូនថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈអគ្គនាយកដ្ឋាន លើគម្រោងចំណូល ចំណាយថវិកា និងគម្រោងវិនិយោគប្រចាំឆ្នាំរបស់សហគ្រាសសាធារណៈ ដើម្បីធ្វើការពិនិត្យសម្រេច ក្នុងនាមជាក្រសួងអាណាព្យាបាលហិរញ្ញវត្ថុ
- ជំរុញការបង់ចំណូលចូលថវិកាជាតិរបស់សហគ្រាសសាធារណៈ
- ធ្វើរបាយការណ៍សរុបស្តីពីសកម្មភាពការងាររបស់សាមីការិយាល័យ និងរបស់នាយកដ្ឋានសហគ្រាសសាធារណៈ។

**ប្រការ២៨.-**

តួនាទី និងភារកិច្ចរបស់ការិយាល័យគ្រឹះស្ថានសាធារណៈរដ្ឋបាល មានដូចខាងក្រោម៖
- ចូលរួមផ្តួចផ្តើម និងរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ និងលិខិតបទដ្ឋានគតិយុត្តសម្រាប់ការកែទម្រង់គ្រឹះស្ថានសាធារណៈរដ្ឋបាល ស្របតាមការរីកចម្រើន នៃសេដ្ឋកិច្ចជាតិ
- ជំរុញ និងរៀបចំអង្គភាពរដ្ឋដែលជាគោលដៅនៃការកែទម្រង់ទៅជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- ផ្តួចផ្តើម និងចូលរួមរៀបចំ និងពិនិត្យក្របខ័ណ្ឌច្បាប់លិខិតបទដ្ឋានពាក់ព័ន្ធនានា រួមទាំងការកំណត់ដើមទុនដំបូង ឬ ការជម្រះបញ្ជីសម្រាប់ការបង្កើត ការបញ្ចូលគ្នា ការបែកចេញ ការប្រែប្រួល ការរំសាយ ឬ ការកែលម្អនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- ពិនិត្យការបិទបញ្ជីគណនេយ្យប្រចាំឆ្នាំ ព្រមទាំងតាមដានស្ថានភាពប្រែប្រួល នៃបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលនីមួយៗ
- ពិនិត្យវាយតម្លៃ និងធ្វើការជម្រះបញ្ជីចលនទ្រព្យ និងអចលនទ្រព្យរបស់គ្រឹះស្ថាន

សាធារណៈរដ្ឋបាល ដែលផុតអាយុកាលប្រើប្រាស់ ឬ ខូចខាត
- តាមដាន និងពិនិត្យជាប្រចាំអំពីស្ថានភាពហិរញ្ញវត្ថុរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល
- ពិនិត្យគម្រោងថវិកាប្រចាំឆ្នាំ និងគម្រោងវិនិយោគរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ដើម្បីបញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំនីមួយៗ
- ធ្វើរបាយការណ៍ទៀងទាត់ស្តីពីសកម្មភាពការងាររបស់ការិយាល័យសាមី ។

**ប្រការ២៩.-**

តួនាទី និងភារកិច្ចរបស់ការិយាល័យអង្គភាពនីតិបុគ្គលសាធារណៈមានដូចខាងក្រោម÷
- ចូលរួមផ្តួចផ្តើម និងរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ និងលិខិតបទដ្ឋានគតិយុត្ត សម្រាប់ការកែទម្រង់អង្គភាពនីតិបុគ្គលសាធារណៈ ស្របតាមការរីកចម្រើននៃសេដ្ឋកិច្ចជាតិ
- គ្រប់គ្រងអង្គភាពនីតិបុគ្គលសាធារណៈ អង្គភាពរដ្ឋនានាស្ថិតនៅក្រោមចំណុះរបស់ក្រសួង ស្ថាប័ន ដែលមានប្រភពចំណូលផ្សេងទៀតក្រៅពីថវិការដ្ឋ
- ជំរុញ និងរៀបចំអង្គភាពរដ្ឋ ឬ អង្គភាពនីតិបុគ្គលសាធារណៈ ដែលជាគោលដៅនៃការកែទម្រង់ទៅជាសហគ្រាសសាធារណៈឬ គ្រឹះស្ថានសាធារណៈរដ្ឋបាល
- ពិនិត្យការបិទបញ្ជីគណនេយ្យប្រចាំឆ្នាំ ព្រមទាំងតាមដានស្ថានភាពប្រែប្រួល នៃបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ របស់អង្គភាពនីតិបុគ្គលសាធារណៈនីមួយៗ ហើយបញ្ជូនបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់អង្គភាពនីតិបុគ្គលសាធារណៈមួយច្បាប់ដើម្បីតម្កល់ទុកនៅនាយកដ្ឋានសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ នៃអគ្គនាយកដ្ឋាន
- តាមដាននិងពិនិត្យជាប្រចាំអំពីស្ថានភាពហិរញ្ញវត្ថុរបស់អង្គភាពនីតិបុគ្គលសាធារណៈ
- ពិនិត្យវាយតម្លៃ និងធ្វើការជម្រះបញ្ជីចលនទ្រព្យនិងអចលនទ្រព្យរបស់អង្គភាពនីតិបុគ្គលសាធារណៈ ដែលផុតអាយុកាលប្រើប្រាស់ ឬ ខូចខាត
- ពិនិត្យគម្រោងថវិកាប្រចាំឆ្នាំនិងគម្រោងវិនិយោគរបស់អង្គភាពនីតិបុគ្គលសាធារណៈ ដើម្បីបញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំនីមួយៗ
- ធ្វើរបាយការណ៍ទៀងទាត់ស្តីពីសកម្មភាពការងាររបស់ការិយាល័យសាមី ។

## ជំពូកទី៧

## លេខាធិការដ្ឋាន

**ប្រការ៣០.-**

លេខាធិការដ្ឋាននៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ

លើបេសកកម្មដូចតទៅ÷

- ជាជំនួយការឱ្យអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ ក្នុងការសម្របសម្រួលការងាររវាងនាយកដ្ឋាន និងការិយាល័យរបស់អគ្គនាយកដ្ឋាន
- ធ្វើជាសេនាធិការឱ្យអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ លើការងាររដ្ឋបាល ហិរញ្ញវត្ថុ បុគ្គលិក និងការបណ្តុះបណ្តាល
- បូកសរុបរបាយការណ៍នៃសកម្មភាពការងារ និងធ្វើកំណត់ហេតុប្រជុំរបស់អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ ។

## ជំពូកទី៨

## អវសានប្បញ្ញត្តិ

**ប្រការ៣១.-**

ក្នុងការបំពេញភារកិច្ចទាំងឡាយណាដែលពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់អគ្គនាយកដ្ឋាន នាយកដ្ឋានជំនាញដទៃនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ ត្រូវសហការជាមួយអគ្គនាយកដ្ឋានពាក់ព័ន្ធទាំងនោះ រួមគ្នាដោះស្រាយ ឬ សុំការសម្រេចពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើការកំណត់ ឬ បែងចែកភារកិច្ចទាំងនោះ ។

**ប្រការ៣២.-**

ត្រូវបានទុកជានិរាករណ៍ នូវប្រកាសដូចខាងក្រោម÷

- ប្រកាសលេខ ១៧១ សហវ.ប្រក ចុះថ្ងៃទី០៧ ខែ មីនា ឆ្នាំ ២០០១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ប្រកាសលេខ២៣៦ សហវ.ប្រក ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០០៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋានចំណូលមិនមែនសារពើពន្ធ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ប្រកាសលេខ១៤៧សហវ.ប្រក ចុះថ្ងៃទី១៥ខែកុម្ភៈឆ្នាំ២០១៣ ស្តីពីការបង្កើតការិយាល័យសម្បទានដីសេដ្ឋកិច្ចបន្ថែមលើប្រកាសលេខ ១៧១ សហវ.ប្រក ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០០១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**ប្រការ៣៣.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ អគ្គលេខាធិការ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋានក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៩ ខែ ធ្នូ ឆ្នាំ ២០១៣

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានីខេត្ត
- ដូចប្រការ៣៣
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

ឧបសម្ព័ន្ធនៃប្រកាសលេខ......
ចុះថ្ងៃទី.........ខែ.........ឆ្នាំ.........

**អង្គភាពលេខរបស់អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ**

